សហប្រជាជាតិ

A

ការបកប្រែក្រៅផ្លូវការ

# មហាសន្និបាត

ចែកចាយទូទៅ

A/HRC/4/95
ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៧

ច្បាប់ដើម : ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
សម័យប្រជុំលើកទី៤
ចំណុចទី២ នៃរបៀបវារៈបណ្ដោះអាសន្ន

## ការអនុវត្តន៍សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ៦០/២៥១ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ដែលមានចំណងជើងថា " ក្រុមប្រឹក្សាសិទ្ធិមនុស្ស "

## តួនាទីនិងសមិទ្ធិផលសំរេចបានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស

## របាយការណ៍របស់លោកអគ្គលេខាធិការអ.ស.ប

# សេចក្ដីសង្ខេប


របាយការណ៍នេះ ត្រូវបានរៀបចំឡើងស្របតាមសេចក្ដីសំរេចលេខ ២/១០២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ របាយការណ៍នេះផ្ដល់សេចក្ដីអធិប្បាយអំពីសកម្មភាពការងារនៅកម្ពុជា របស់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ចាប់ពីខែមករា រហូតដល់ពាក់កណ្ដាលខែធ្នូ ឆ្នាំ២០០៦ ។

នៅក្នុងពេលធ្វើរបាយការណ៍នេះ ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជាបានបន្ដឃ្លាំមើលស្ថានការណ៍សិទ្ធិមនុស្សទូទៅ ។ ការិយាល័យបានឆ្លើយតបចំពោះរបាយការណ៍នៃការរំលោភសិទ្ធិមនុស្ស និងធ្វើការពាំនាំជាប្រចាំនូវកង្វល់របស់ខ្លួនប្រាប់អាជ្ញាធរជាតិ និងអាជ្ញាធរខេត្ត-ក្រុង ដើម្បីសុំការជួយធ្វើអន្ដរាគមន៍ និងការដោះស្រាយ ។ ការិយាល័យបានផ្ដល់អាទិភាពលើបញ្ហាទាំងឡាយ ដែលបានប្រឈមមុខដោយអង្គការក្រៅរដ្ឋាភិបាល(NGOs) ក្រុម និងបុគ្គលទាំងឡាយដែលការពារសិទ្ធិមនុស្សក្នុងការអនុវត្តការងាររបស់ខ្លួន ។

នៅក្នុងវិស័យកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការិយាល័យបានបន្តធ្វើការតស៊ូមតិឱ្យមានកំណែទម្រង់រចនាសម្ព័ន្ធស្ថាប័នសំខាន់ៗមួយចំនួន ដើម្បីធានាការពារប្រព័ន្ធតុលាការមួយដែលឯករាជ្យ និងវិជ្ជាជីវៈ និងបានរួមចំណែកក្នុងការបង្កើតច្បាប់ឱ្យស្របតាមសិទ្ធិសញ្ញាសិទ្ធិមនុស្សអន្ដរជាតិ ដែលប្រទេសកម្ពុជាជាភាគី ។

ការិយាល័យបានឃ្លាំមើលការអនុវត្តន៍ច្បាប់ភូមិបាលឆ្នាំ២០០១ ដោយផ្ដោតទៅលើការផ្ដល់ និងផលប៉ះពាល់នៃដីសេដ្ឋកិច្ច និងសម្បទានដទៃទៀតនៃធនធានធម្មជាតិកម្ពុជា ដោយគិតគូជាពិសេសចំពោះជនជាតិដើមភាគតិចកម្ពុជា ។

ការិយាល័យបានធ្វើសហប្រតិបត្តិការជាមួយស្ថាប័នទាំងបីនៃរដ្ឋាភិបាល ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ពហុភាគី និងទ្វេរភាគី ក៏ដូចជា ជាមួយអង្គការក្រៅរដ្ឋាភិបាលជាច្រើន និងអង្គការសង្គមស៊ីវិលដទៃទៀត ។

តាមរយៈសកម្មភាពអប់រំនិងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈរបស់ខ្លួន ការិយាល័យបានខិតខំលើកកំពស់ការយល់ដឹងថែមទៀត អំពីលិខិតុបករណ៍សិទ្ធិមនុស្សអន្ដរជាតិ និងការអនុវត្តន៍លិខិតុបករណ៍ទាំងនោះនៅថ្នាក់ជាតិ និងដើម្បីបង្កបរិយាកាសងាយស្រួលសំរាប់ការងារសិទ្ធិមនុស្ស ។

លោកស្រីឧត្តមស្នងការបច្ចុប្បន្ន បានធ្វើទស្សនកិច្ចលើកដំបូងមកកាន់ប្រទេសកម្ពុជាក្នុងខែឧសភាកន្លងមកនេះ។ នៅក្នុងពេលធ្វើទស្សនកិច្ចនេះ លោកស្រីបានផ្តោតការយកចិត្តទុកដាក់អំពីសារៈសំខាន់នៃប្រព័ន្ធតុលាការមួយដែលឯករាជ្យ និងវិជ្ជាជីវៈ ក្នុងការការពារសិទ្ធិមនុស្ស និងសេរីភាព និងអំពីលទ្ធភាពរបស់សកម្មជនសង្គមស៊ីវិល ដើម្បីធ្វើការដោយសេរី និងដោយសុវត្ថិភាព។

ការិយាល័យក៏បានជួយសំរួលដល់បេសកកម្មលើកទីពីរ របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងខែមីនា ក៏ដូចជា ដំណើរទស្សនកិច្ចក្រៅផ្លូវការរបស់តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសកម្មជនសិទ្ធិមនុស្សក្នុងខែធ្នូកន្លងទៅនេះ ដើម្បីចូលរួមក្នុងពិធីរំលឹកខួបទិវាសិទ្ធិមនុស្សអន្តរជាតិ។

# មាតិកា

*កថាខ័ណ្ឌ ទំព័រ*

I. សេចក្តីផ្តើម ........................................................................................................ 1-6

II. ដំណើរទស្សនកិច្ចរបស់ឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ................................ 7

III. ការជួយឧបត្ថម្ភដល់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ....................................................................... 43 – 58

IV. សកម្មភាពការងាររបស់ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកស្ទួយ និង ការការពារសិទ្ធិមនុស្ស.................................................................................... 59 – 63

ក. គោលដៅទូទៅ .................................................................................... 64 -67

ខ. កម្មវិធីការពារ .................................................................................... 71 – 77

គ. នីតិរដ្ឋ និងវិស័យយុត្តិធម៌ ........................................................................ 71 – 77

ឃ. និទណ្ឌភាព........................................................................................ 71 – 77

ង. ដីធ្លី និងការចិញ្ចឹមជីវិត .......................................................................... 71 – 77

ច. ការប្រកាន់ខ្ជាប់នូវសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ........................................... 71 – 77

ឆ. ស្ថាប័នសិទ្ធិមនុស្សជាតិ ........................................................................... 71 – 77

ជ. កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយ ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា .................................................... 71 – 77

ឈ. កម្មវិធីអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយព័ត៌មានសាធារណៈ ....................... 71 – 77

V. កិច្ចការបុគ្គលិក និងរដ្ឋបាលរបស់ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា.................................................................... 94 – 100

# I. សេចក្តីផ្តើម

១. របាយការណ៍នេះ ត្រូវបានដាក់ស្នើស្របតាមសេចក្តីសំរេចលេខ ២/១០២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលក្នុងនោះ ក្រុមប្រឹក្សានេះបានស្នើឱ្យលោកអគ្គលេខាធិការ និងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបន្តអនុវត្តសកម្មភាពការងាររបស់ខ្លួន ស្របតាមសេចក្តីសំរេចទាំងអស់កន្លងមក ដែលបានអនុម័តដោយគណៈកម្មការសិទ្ធិមនុស្ស និងធ្វើបច្ចុប្បន្នភាពរបាយការណ៍ និងការសិក្សាផ្សេងៗដែលពាក់ព័ន្ធ ។

២. ការិយាល័យប្រចាំកម្ពុជា របស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ បន្ទាប់ពីការដកចេញនៃអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា(UNTAC) ។ អាណត្តិការិយាល័យនេះ និងអាណត្តិតំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា កើតចេញពីសេចក្តីសំរេចចិត្តលេខ១៩៩៣/៦ របស់គណៈកម្មការសិទ្ធិមនុស្ស ។ អាណត្តិទាំងនេះរួមមានមុខងារតាមឃ្លាំមើលការការពារ និងការធ្វើរបាយការណ៍សាធារណៈ ជាមួយនឹងការផ្តល់ជំនួយផ្នែកបច្ចេកទេស និងសេវាប្រឹក្សាយោ បល់ ។

៣. ការិយាល័យប្រចាំកម្ពុជា បានបន្តគ្រប់គ្រងដោយសេចក្តីសំរេចចិត្តលេខ២០០៥/៧៧ របស់គណៈកម្មការសិទ្ធិមនុស្សដែលបានអញ្ជើញលោកអគ្គលេខាធិការ ទីភ្នាក់ងារនៃប្រព័ន្ធអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលនានាឱ្យបន្តជួយដល់រដ្ឋាភិបាលក្នុងការធានាការពារ និងការលើកស្ទួយសិទ្ធិប្រជាជនកម្ពុជាគ្រប់រូប ។

៤. ទន្ទឹមនឹងកត់សំគាល់ពីការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា គណៈកម្មការនេះមានកង្វល់ដោយសារថា ការរំលោភសិទ្ធិមនុស្សនៅតែបន្តកើតមាន ជាពិសេសការរំលោភលើវិធានច្បាប់ ប្រព័ន្ធតុលាការ ការជួញដូរមនុស្ស អំពើហឹង្សាប្រឆាំងនឹងសកម្មជននយោបាយ និងសកម្មជនស៊ីវិល និទណ្ឌភាព និងអំពើពុករលួយ ។ គណៈកម្មការបានស្នើទៅរដ្ឋាភិបាលឱ្យពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន នៅក្នុងវិស័យជាក់លាក់មួយចំនួនដោយរួមទាំង :

- ការអនុម័ត និងការអនុវត្តន៍ច្បាប់ និងក្រមសំខាន់ៗ សំរាប់ការបង្កើតសង្គមប្រជាធិបតេយ្យមួយយ៉ាងពេញលេញ ។

- ការធានាឯករាជ្យភាព ភាពមិនលំអៀង និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធមិ

- ការស៊ើបអង្កេត និងការផ្តន្ទាទោសជនទាំងឡាយ ដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ រួមទាំងការរំលោភសិទ្ធិមនុស្ស

- ការបំពេញកាតព្វកិច្ចរបស់កម្ពុជា ក្រោមលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ

- ការប្រយុទ្ធប្រឆាំងនឹងបញ្ហាគន្លឹះមួយចំនួន ដូចជាការជួញដូរមនុស្ស បញ្ហាទាក់ទងនឹងភាពក្រីក្រ អំពើហឹង្សាផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

- ការដោះស្រាយបញ្ហាកម្មសិទ្ធិដីធ្លី ក្នុងលក្ខណៈបើកចំហ និងត្រឹមត្រូវ ។

- បង្កើតបរិយាកាសងាយស្រួលសំរាប់ការធ្វើសកម្មភាពនយោបាយស្របច្បាប់ និងការគាំទ្រដល់តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីពង្រឹងការអភិវឌ្ឍន៍លិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

៥. ការិយាល័យក៏បានធ្វើការស្របតាមលក្ខខណ្ឌនៃអនុស្សារណៈថ្មីនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សំរាប់ការអនុវត្តន៏កម្មវិធីសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស ដែលបានចូលជាធរមាននៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៥ សំរាប់រយៈពេលពីរឆ្នាំ ។ កម្មវិធីនេះរួមមាន :

- ការផ្តល់ជំនួយឧបត្ថម្ភដល់រដ្ឋាភិបាល ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស

- ការលើកកំពស់សមាហរណកម្មឱ្យកាន់តែច្រើនថែមទៀតទៅក្នុងវិស័យសិទ្ធិមនុស្ស នូវកម្មវិធីអប់រំសុខាភិបាល និងកម្មវិធីអភិវឌ្ឍន៍ដទៃទៀត

- ផ្តល់ការជួយគាំទ្រផ្នែកបច្ចេកទេស សំរាប់កម្មវិធីកំណែទម្រង់របស់រដ្ឋាភិបាល ដោយរួមទាំងក្នុងវិស័យនៃការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ និងនីតិវិធីនីតិកម្ម

- ជំរុញលើកទឹកចិត្តឱ្យមានការចូលរួមពីសង្គមស៊ីវិល និងលើកកំពស់ការអប់រំដល់សាធារណៈជនអំពីលិទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស

- ផ្តល់ តាមការស្នើសុំរបស់រដ្ឋាភិបាល នូវជំនួយផ្នែកបច្ចេកទេស និងការណែនាំក្នុងការបំពេញការទទួលខុសត្រូវ ដោយរួមទាំងការដាក់ស្នើរបាយការណ៍ ស្របតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួន និងការណែនាំ និងការជួយឧបត្ថម្ភដល់រដ្ឋាភិបាល និងដៃគូសង្គមស៊ីវិលរបស់ខ្លួន ក្នុងការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ។

៦. ក្នុងឆ្នាំ២០០៦ កម្មវិធីនៅកម្ពុជារបស់ការិយាល័យនេះ ត្រូវបានអនុវត្តក្នុងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននានារបស់រដ្ឋាភិបាល ដែលមានការទទួលខុសត្រូវក្នុងវិស័យសិទ្ធិមនុស្ស ដោយរួមទាំងស្ថាប័នតុលាការ និងតុលាការនានា គណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាមួយអាជ្ញាធរខេត្ត-ក្រុងនានា ។ ការិយាល័យបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល និងអង្គការប្រចាំសហគមន៍ និងក្រុមអ្នកធ្វើការលើបញ្ហាសិទ្ធិមនុស្ស ច្បាប់ និងការអភិវឌ្ឍន៍ ។

## II. ដំណើរទស្សនកិច្ចរបស់ឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស

៧. លោកស្រី **លូីស អាប៊ួរ** ឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស បានធ្វើទស្សនកិច្ចលើកដំបូងមកកាន់ប្រទេសកម្ពុជាក្នុងខែឧសភាកន្លងមកនេះ ។ នៅក្នុងពេលបំពេញទស្សនកិច្ច លោកស្រីឧត្តមស្នងការបានធ្វើការពិភាក្សាយ៉ាងវិជ្ជមានជាមួយលោកនាយករដ្ឋមន្ត្រីអំពីការបន្តអាណត្តិរបស់ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ។ នៅចុងបញ្ចប់នៃបេសកកម្មរបស់លោកស្រី លោកស្រីឧត្តមស្នងការបានចេញសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះ :

ខ្ញុំមានកិត្តិយសណាស់ ដែលបានមកបំពេញបេសកកម្មលើកដំបូងនៅកម្ពុជា ជាប្រទេសមួយដែលការិយាល័យខ្ញុំបាននិងកំពុងប្រតិបត្តិការរហូតមកទល់ពេលនេះមានរយៈពេលជាងមួយទសវត្សហើយ ។ ខ្ញុំបានទទួលបុព្វសិទ្ធិចូលគាល់ព្រះមហាក្សត្រ និងបានជួបជាមួយលោក ហ៊ុនសែន នាយករដ្ឋមន្ត្រី លោក ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក សុខ អាន ឧបនាយករដ្ឋមន្ត្រី និងលោក អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ខ្ញុំក៏បានជួបជាមួយតំណាងជាច្រើននៃអង្គការសង្គមស៊ីវិលកម្ពុជា ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា សមាជិកនៃសហគមន៍អ្នកការទូត និងមន្ត្រីនៃអង្គជំនុំជំរះវិសាមញ្ញ សំរាប់តុលាការខ្មែរក្រហម ។

ដំណើរទស្សនកិច្ចនេះ បានផ្តល់ឱកាសឱ្យខ្ញុំបានស្វែងយល់ថែមទៀតអំពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ។ គេបានប្រាប់ខ្ញុំម្តងហើយម្តងទៀតអំពីការវិវត្តន៍ជាវិជ្ជមានក្នុងប្រទេសនេះចាប់តាំងពីឆ្នាំ១៩៩៣ រួមទាំងស្ថិរភាពបន្ទាប់ពីសង្គ្រាមជាច្រើនឆ្នាំមក ការរីកចំរើនខាងសេដ្ឋកិច្ច និងការរៀបចំបោះឆ្នោតជាទៀតទាត់ ។ ជាការពិតណាស់ មិនមានប្រទេសណាមួយមានរបាយការណ៍សិទ្ធិមនុស្សល្អឥតខ្ចោះឡើយ ។ ខ្ញុំជឿថាសញ្ញាដែលល្អបំផុតនៃការរីកចំរើនចុងក្រោយនោះគឺ សមត្ថភាពក្នុងការទទួលស្គាល់អំពីចំណុចខ្វះខាត ។ ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជាបាន និងកំពុងស្ថិតក្រោមការវិភាគយ៉ាងទូលំទូលាយដោយតំណាងពិសេសបន្តបន្ទាប់គ្នាចំនួនបួនរូបរបស់លោកអគ្គលេខាធិការអ.ស.ប ។ សេចក្តីសន្និដ្ឋានរបស់តំណាងពិសេសទាំងនេះ បង្ហាញពីការខុបសគ្គជាច្រើនដែលប្រទេសកម្ពុជានៅមិនទាន់ជំនះបាន ។

ដំណើរទស្សនកិច្ចនេះ បានអនុញ្ញាតឱ្យខ្ញុំផ្តោតលើបញ្ហាមួយ ដែលខ្ញុំយល់ថាមានសារសំខាន់បំផុតសំរាប់ការពង្រឹងលិទ្ធិប្រជាធិបតេយ្យក្រោមនីតិរដ្ឋ ដែលគេហៅថា ការពង្រឹងស្ថាប័នតុលាការរបស់រដ្ឋាភិបាល ។ ប្រព័ន្ធតុលាការមួយឯករាជ្យ និងវិជ្ជាជីវៈ ដែលត្រូវបានគេទទួលស្គាល់អំពីសេចក្តីសុច្ចរិតនោះ មិនត្រឹមតែមានសារៈសំខាន់ក្នុងការការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចជួយដោះស្រាយការលំបាកជាច្រើនដែលមាននៅកម្ពុជា រួមទាំងបញ្ហានិទណ្ឌភាព ជំលោះដីធ្លី និងអំពើពុករលួយ ។

លទ្ធភាពនៃតួអង្គសង្គមស៊ីវិលក្នុងការធ្វើការងារដោយសេរី និងដោយសុវត្ថិភាព គឺជាសន្ទស្សន៍ជាគន្លឹះមួយទៀត នៃដំណើរការប្រជាធិបតេយ្យ ។ វិជ្ជាជីវៈនិយម និងការប្តេជ្ញាចិត្តរបស់អង្គការក្រៅរដ្ឋាភិបាល គឺជាទ្រព្យសម្បត្តិមួយដ៏អស្ចារ្យសំរាប់ការអភិវឌ្ឍន៍ប្រទេស ហើយវាជាទ្រព្យសម្បត្តិមួយដែលត្រូវតែធានាការពារ និងគាំទ្រ ។

ដំណើរទស្សនកិច្ចរបស់ខ្ញុំមកកម្ពុជា ធ្វើឡើងនៅក្នុងខណៈពេលមួយដែលប្រព័ន្ធសិទ្ធិមនុស្សពិភពលោកមានការប្រែប្រួលច្រើន ។ អង្គការអន្តរដ្ឋាភិបាលថ្មីមួយគឺក្រុមប្រឹក្សាសិទ្ធិមនុស្សនឹងជួបប្រជុំលើកដំបូងនៅខែក្រោយនេះ ។ ក្នុងចំណោមភារកិច្ចជាច្រើនរបស់អង្គការនេះ រួមមានការពិនិត្យឡើងវិញនូវរបាយការណ៍សិទ្ធិមនុស្សរបស់រដ្ឋសមាជិកអង្គការសហប្រជាជាតិ ។ម្យ៉ាងវិញទៀត មានការបញ្ជាក់យ៉ាងច្បាស់ថា ស្ថានការណ៍សិទ្ធិមនុស្សក្នុងប្រទេសនីមួយៗ គឺជាកង្វល់ស្របច្បាប់របស់សហគមន៍អន្តរជាតិ ។ អាស្រ័យហេតុនេះ ខ្ញុំមានការជឿជាក់ចំពោះកម្ពុជា ដោយសារថារដ្ឋាភិបាលនៃប្រទេសនេះ បានសំដែងការប្តេជ្ញាចិត្តពង្រឹងកិច្ចសហប្រតិបត្តិការរយៈពេលយូរអង្វែងជាមួយការិយាល័យ និងបានប្តេជ្ញាចិត្តធានាឱ្យការងារយើងមានផ្លែផ្កា ប្រយោជន៍ដល់ការការពារសិទ្ធិមនុស្សនៅកម្ពុជា ។

## III. ការជួយឧបត្ថម្ភដល់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

៨. ការិយាល័យប្រចាំកម្ពុជាបានបន្តគាំទ្រដល់តំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការបំពេញអាណត្តិរបស់ខ្លួន ក្នុងការរក្សាទំនាក់ទំនងជាមួយរដ្ឋាភិបាល និងប្រជាជនកម្ពុជា និងជួយរដ្ឋាភិបាលនេះ ក្នុងការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស ។ ការិយាល័យបានបន្តរាយការណ៍ជាប្រចាំទៅលោកតំណាងពិសេសអំពីការវិវត្តន៍ថ្មីៗ បានរាយការណ៍អំពីបញ្ហាដែលជាកង្វល់ជាក់ស្តែងមួយចំនួន និងបានជួយសំរួលដល់បេសកកម្មលើកទីពីររបស់លោកតំណាងពិសេសមកកម្ពុជាក្នុងខែមីនាកន្លងមកនេះ ។ (សូមមើលរបាយការណ៍លេខ A/HRC/4/36 សំរាប់អនុសាសន៍របស់លោកជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស) ។

៩. លោក **យាស្ស ហ្គាយ** តំណាងពិសេសបច្ចុប្បន្ន បានចូលបំរើការងារចាប់ពីខែវិច្ឆិកា ឆ្នាំ២០០៥ ។ តំណាងពិសេសមុខៗមានលោក **ភីធី លំយប្រេក** (២០០០ - ២០០៥) **លោក ថូម៉ាស់ ហាំម៉ាបឺក** (១៩៩៦ - ១៩៩៩) និង លោក **ម៉ៃឃើល យីបី** (១៩៩៣ - ១៩៩៦) ។

## IV. សកម្មភាពការងាររបស់ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស

### ក. គោលដៅទូទៅ

១០. ការិយាល័យប្រចាំកម្ពុជាបានបន្តឆ្លើយតបចំពោះករណី និងស្ថានការណ៍ទាំងឡាយ ដែលត្រូវយកចិត្តទុកដាក់ជាបន្ទាន់ ទន្ទឹមនឹងនោះ ក៏ជួយពង្រឹងសំរាប់រយៈពេលយូរអង្វែង នូវស្ថាប័នទាំងឡាយដែលទទួលខុសត្រូវធានាការពារ និងលើកស្ទួយការគោរពសិទ្ធិមនុស្ស ក៏ដូចជាក្នុងការបង្កើតគោលនយោបាយ ច្បាប់ និងការអនុវត្តន៍ស្របតាមការប្តេជ្ញាចិត្តសិទ្ធិមនុស្សអន្តរជាតិ ។ ការិយាល័យបានរៀបចំរចនាសម្ព័ន្ធការងាររបស់ខ្លួន តាមរយៈកម្មវិធីបីដែលបានផ្សាភ្ជាប់គ្នា ដែលបានផ្តោតលើការឃ្លាំមើល និងការការពារ នីតិរដ្ឋ និងដីធ្លី និងការចិញ្ចឹមជីវិត ។

១១. ការងារជាអាទិភាពរបស់ការិយាល័យនេះ រួមមានការឆ្លើយតបទៅនឹងរបាយការណ៍ស្តីពីការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ផ្តល់លទ្ធភាពឱ្យអង្គការក្រៅរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលអាចអនុវត្តការងាររបស់ខ្លួន ដើម្បីសិទ្ធិ

មនុស្សដោយសុវត្ថិភាព ស្របតាមសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុមនិងអង្គការសង្គម ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល (សេចក្តីប្រកាសស្តីពីសកម្មជនសិទ្ធិមនុស្ស) លើកស្ទួយការគោរពសេរីភាពក្នុងការសំដែងមតិ ការបង្កើតសមាគម និងការប្រជុំ និងរួមចំណែកក្នុងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។ ការិយាល័យបានឃ្លាំមើលការអនុវត្តន៍ច្បាប់ភូមិបាលឆ្នាំ ២០០១ ដោយផ្តោតជាសំខាន់លើការផ្តល់សម្បទានដីសេដ្ឋកិច្ច និងផលប៉ះពាល់របស់វាទៅលើប្រជាពលរដ្ឋមូលដ្ឋាន និងជនជាតិដើមភាគតិចកម្ពុជា ដែលប្រឈមមុខនឹងការផ្ទេរកម្មសិទ្ធិដីរបស់ខ្លួនយ៉ាងឆាប់រហ័ស ។

១២. ការិយាល័យបានធ្វើការជាមួយរដ្ឋាភិបាល ក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា និងជាមួយទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ពហុភាគី និងទ្វេរភាគី ដើម្បីលើកស្ទួយការធ្វើសមាហរណកម្ម និងការអនុវត្តន៍បទដ្ឋានសិទ្ធិមនុស្សនៅក្នុងផែនការអភិវឌ្ឍន៍ គោលនយោបាយ និងការអនុវត្តន៍ថ្នាក់ជាតិ ។

១៣. ការិយាល័យបានខិតខំបង្កបរិយាកាសងាយស្រួលសំរាប់ការអនុវត្តន៍សិទ្ធិមនុស្ស តាមរយៈការលើកកំពស់ ការយល់ដឹងអំពីលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងការប្រតិបត្តិច្បាប់ និងការអនុវត្តន៍ក្នុងស្រុក ផ្សព្វផ្សាយការយល់ដឹង និងវាយតំលៃខ្ពស់ថែមទៀតដល់តួនាទី និងការរួមវិភាគទានរបស់អង្គការក្រៅរដ្ឋាភិបាលនានា ដែលការពារសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម ។

## ៥. កម្មវិធីការពារ

១៤. តាមរយៈកម្មវិធីការពាររបស់ខ្លួន ការិយាល័យប្រចាំកម្ពុជា បានផ្តល់អាទិភាពលើករណីទាំងឡាយដែលអង្គការក្រៅរដ្ឋាភិបាល និងសកម្មជននានាបានប្រឈមមុខនឹងគ្រោះថ្នាក់ ពាក់ព័ន្ធនឹងការងាររបស់ខ្លួនក្នុងការការពារសិទ្ធិមនុស្ស ។ ការិយាល័យក៏បានទទួលដោះស្រាយករណីទាំងឡាយដែលប៉ះពាល់ធ្ងន់ធ្ងរលើស្ថានការណ៍សិទ្ធិមនុស្សជាទូទៅ ។ ការិយាល័យបានធ្វើការពាំនាំនូវកង្វល់របស់ខ្លួនជាប្រចាំប្រាប់ទៅអាជ្ញាធរជាតិ និងអាជ្ញាធរខេត្ត-ក្រុង រួមទាំងតុលាការ ដើម្បីដោះស្រាយ និងជួសជុលការខូចខាតប្រកបដោយប្រសិទ្ធភាព ។ ការិយាល័យបានចាត់វិធានការលើករណីជាច្រើន រួមទាំងករណីពាក់ព័ន្ធនឹងការរិតត្បិតលើសេរីភាពក្នុងការសំដែងមតិ ការបង្កើតសមាគម និងការប្រជុំ ការចាប់ខ្លួនខុសច្បាប់ និងការរំលោភធ្ងន់ធ្ងរផ្សេងៗទៀត លើនីតិវិធីព្រហ្មទណ្ឌដែលបានធានាការពារ ជំលោះដីធ្លី ការទទួលបានដីធ្លីដោយខុសច្បាប់ ការជម្លៀសចេញដោយបង្ខំ និងការប្រើប្រាស់កំលាំងលើសលុប ។ ការិយាល័យបានធ្វើការតស៊ូមតិសំរាប់ច្បាប់ពាក់ពន្ធ័ដែលមានស្រាប់ និងសេចក្តីព្រាងច្បាប់ស្តីពីសេរីភាពជាមូលដ្ឋាន ដើម្បីឱ្យស្របតាមរដ្ឋ

ធម្មនុញ្ញកម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដទៃទៀតដែលកម្ពុជាជាភាគី។ ការិយាល័យក៏បានឃ្លាំមើលនិន្នាការនៃការអនុវត្តន៍សេរីភាពក្នុងការសំដែងមតិ ការបង្កើតសមាគម និងការប្រជុំ។

១៥. នៅដើមឆ្នាំ២០០៦ ការិយាល័យបានតាមឃ្លាំមើលការចាប់ខ្លួនប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអនុប្រធានរបស់គាត់ និងនាយកមជ្ឈមណ្ឌលអប់រំច្បាប់កម្ពុជា។ អ្នកទាំងនោះ ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ពាក់ព័ន្ធនឹងបដាមួយដែលបានដាក់បង្ហាញនៅក្នុងពេលប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ ២០០៥។ បន្ទាប់មកមានការចាប់ខ្លួនជាបន្តបន្ទាប់នៃម្ចាស់និងនាយកស្ថានីយវិទ្យុដ៏មានប្រជាប្រិយមួយ និងប្រធានសមាគមគ្រូបង្រៀនឯករាជ្យក្នុងខែតុលា ឆ្នាំ២០០៥ ពីបទបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់។ បុរសទាំងប្រាំនាក់នេះ ត្រូវបានដោះលែងនៅពាក់កណ្តាលខែមករាកន្លងមកនេះ ប៉ុន្តែការចោទប្រកាន់នៅតែព្យួរដដែល។

១៦. នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០០៦ លោកស្រីឧត្តមស្នងការបានចេញសេចក្តីថ្លែងការណ៍មួយសំដែងនូវការសោកស្តាយ និងកង្វល់យ៉ាងខ្លាំងអំពីបណ្តឹង និងការចាប់ខ្លួនសមាជិកសង្គមស៊ីវិល ដែលនាំឱ្យមានការរំខាន និងបានគំរាមកំហែងដល់ការរីកចំរើននៅទសវត្សកន្លងមក ក្នុងការកសាងសង្គមមួយបើកចំហរ និងយុត្តិធមិ ផ្អែកលើនីតិរដ្ឋ។

១៧. នៅថ្ងៃទី២៦ ខែឧសភា រដ្ឋសភាបានអនុម័តវិសោធនកម្មមាត្រា៦៣ នៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ដែលគេស្គាល់ជាទូទៅថាច្បាប់អ៊ុនតាក់។ វិសោធនកម្មនេះបានដកទោសដាក់ពន្ធនាគារ ក្នុងករណីនៃការផ្តន្ទាទោសពីការបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ ប៉ុន្តែបានរក្សាទុកនូវទោសពិន័យជាប្រាក់ពី ២៥០ - ២៥០០ ដុល្លារ។

១៨. ការិយាល័យបានចងក្រងករណីជាបន្តបន្ទាប់ ពាក់ព័ន្ធនឹងការចោទប្រកាន់ពីការផ្សាយព័ត៌មានមិនពិត ហើយមានកង្វល់អំពីនិន្នាការទៅរកការប្រើប្រាស់ការចោទប្រកាន់ពីការផ្សាយព័ត៌មានមិនពិត ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូត ដល់បី ឆ្នាំ ហើយអនុញ្ញាតឱ្យឃុំខ្លួនរង់ចាំសវនាការ ជាការជំនួសឱ្យបទបរិហារកេរ្តិ៍។

១៩. នៅក្នុងពេលធ្វើសេចក្តីរាយការណ៍នេះ ការស្នើសុំធ្វើបាតុកម្ម ការដើរជាក្បួន និងការប្រមូលផ្តុំជាសាធារណៈនៅទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្ត-ក្រុងនានា ត្រូវបានបដិសេធជាប្រចាំ។ ការិយាល័យបានចងក្រងឯកសារទាក់ទងឧប្បត្តិហេតុនៃការប្រើប្រាស់កំលាំងលើសលុបដោយនគរបាលប្រដាប់អាវុធប្រឆាំងកុប្បកម្ម ជាពិសេសពាក់ព័ន្ធនឹងកូដកម្មរបស់សហជីពកម្មករក្នុងវិស័យកាត់ដេរ។ វាមានការចូលរួមពីអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ក្នុងការបង្ការការរីករាលដាលនៃអំពើហឹង្សានៅក្នុងករណីខ្លះ។

២០. ការិយាល័យបានតាមឃ្លាំមើលការជម្លៀសចេញនៃសហគមន៍ក្រីក្រដែលរស់នៅក្នុងទីតាំងក្រៅផ្លូវការនៅកណ្តាលទីក្រុងភ្នំពេញ នៅក្នុងអំឡុងពេលចាប់ពីខែឧសភា ដល់ខែកក្កដា ។ ការិយាល័យបានធ្វើការជាមួយអាជ្ញាធរនានា ក្នុងការបង្ការការប្រើប្រាស់កំលាំង និងដើម្បីសំរាលដល់ផលប៉ះពាល់នៃការជម្លៀសចេញ ។ ក្នុងលិខិតទាក់ទង និងក្នុងការជួបប្រជុំជាមួយអាជ្ញាធរនានា ការិយាល័យបានសំដែងកង្វល់ថា ការជម្លៀសប្រជាពលរដ្ឋចេញនេះ គឺផ្ទុយទៅនឹងកាតព្វកិច្ចរបស់កម្ពុជាក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ ការិយាល័យបានស្នើឱ្យបញ្ឈប់ការតាំងទីលំនៅថ្មី នៅតំបន់ដែលគ្មានមនុស្សរស់នៅៗខាងក្រៅទីក្រុង ដែលខ្វះខាតទឹក អានាម័យ និងទីជំរក ហើយបានគូសបញ្ជាក់ថា ការជម្លៀសចេញគួរតែជាមធ្យោបាយចុងក្រោយ មិនគួរជាមធ្យោយដំបូងនោះឡើយ ។ ការិយាល័យបានស្នើយ៉ាងទទូចឱ្យធ្វើការពន្យាពេល រហូតដល់មានវិធានការគ្រប់គ្រាន់ ដើម្បីធានាឱ្យមានការពិគ្រោះយោបល់ពិតប្រាកដ ការដោះស្រាយតាមផ្លូវច្បាប់ និងការផ្តល់សំណងសមស្របដល់ជនរងគ្រោះ ប្រសិនបើការតាំងទីលំនៅថ្មីនោះមិនអាចជៀសផុត ។ ការិយាល័យបានគូបញ្ជាក់អំពីការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងការការពារសុខភាព និងសុវត្ថិភាពរបស់ជនរងគ្រោះដោយការជម្លៀសចេញ និងបានស្នើឱ្យអាជ្ញាធរនានា អនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលផ្តល់ជំនួយមនុស្សធម៌ នៅពេលដែលអង្គការក្រៅរដ្ឋាភិបាលទាំងនោះត្រូវបានរារាំងមិនឱ្យធ្វើដូច្នោះ ។

២១. ការិយាល័យបានចងក្រងឯកសារពាក់ព័ន្ធនឹងការបន្តិតត្បិតលើសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល និងសកម្មជនសហគមន៍ទាំងឡាយនៅក្នុងខេត្តមួយចំនួន ។ ការិយាល័យមានកង្វល់ថា អភិបាលខេត្ត-ក្រុងខ្លះបានបន្តធ្វើការបកស្រាយខុសចំពោះគោលការណ៍ណែនាំ ដែលក្រសួងមហាផ្ទៃបានចេញក្នុងខែមិថុនា ឆ្នាំ២០០៥ ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងការគ្រប់គ្រងការងាររបស់អង្គការក្រៅរដ្ឋាភិបាល និងសកម្មជនសហគមន៍នានា ឧទាហរណ៍ ការស្នើឱ្យអង្គការក្រៅរដ្ឋាភិបាលផ្តល់ឱ្យខ្លួនយ៉ាងទៀតទាត់ នូវរបាយការណ៍ស្តីពីសកម្មភាព និងគំរោងផែនការនានា និងដោយតម្រូវឱ្យអង្គការក្រៅរដ្ឋាភិបាល និងសកម្មជនសហគមន៍ស្នើសុំការអនុញ្ញាត មុននឹងទៅចូលរួមប្រជុំនៅខាងក្រៅខេត្ត ។ អង្គការក្រៅរដ្ឋាភិបាលនានា និងការិយាល័យបានបន្តស្នើឱ្យក្រសួងពិនិត្យ និងកែប្រែគោលការណ៍ណែនាំនោះ ។

២២. ការិយាល័យក៏បានតាមដានការពិភាក្សាអំពីសេចក្តីព្រៀងច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល ដែលស្ថិតក្នុងការពិចារណាតាំងពីឆ្នាំ១៩៩៥ ដែលរដ្ឋាភិបាលបានពិនិត្យឡើងវិញក្នុងឆ្នាំ២០០៥ នៅពេលដែលក្រសួងមហាផ្ទៃបានស្នើឱ្យធនាគារពិភពលោកជួយព្រៀងច្បាប់នេះ ។ ធនាគារពិភពលោកបានបញ្ជាក់ជាសាធារណៈថា ច្បាប់បែបនេះពិតជាមិនចាំបាច់ទេ ហើយបានស្នើឱ្យរៀបចំកិច្ចដំណើរការពិភាក្សាគ្នារវាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីកំណត់អំពីបញ្ហា និងធ្វើយ៉ាងណាឱ្យបរិយាកាសគោលយោបាយបានល្អប្រសើរឡើង ដើម្បីឱ្យអង្គការក្រៅរដ្ឋាភិបាលអាចរួមចំណែកយ៉ាងរឹងមាំក្នុងការអភិវឌ្ឍន៍ និងការជជែកពិភាក្សាជាសាធារណៈ ។ ទោះជាយ៉ាងណាក៏ដោយ អង្គការ

ក្រៅរដ្ឋាភិបាលខ្លះបានសំដែងភាពស្ទាក់ស្ទើរអំពីបំណងរបស់រដ្ឋាភិបាល និងភាពអល់ឯកក្នុងការចូលរួមក្នុងកិច្ចដំណើរការនេះ នៅក្នុងបរិយាកាសបច្ចុប្បន្ន ពួកគេមានអារម្មណ៍ថាអាចនឹងនាំឱ្យមានការរិតត្បិតមិនសមស្រប ហើយប៉ះពាល់ជាអវិជ្ជមានមកលើការងាររបស់ខ្លួន ។ គេមានកង្វល់ជាពិសេសចំពោះអង្គការក្រៅរដ្ឋាភិបាលដែលការពារសិទ្ធិមនុស្ស ។

២៣. ការិយាល័យបានផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះករណីរបស់ សុខ សំអឿន និង ប៊ិន សំណាង ដែលត្រូវបានផ្តន្ទាទោសពីបទឃាតកម្មលើលោក ជា វិជ្ជា ប្រធានសហជីពកម្មករ ហើយត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគាររយៈពេល២០ ឆ្នាំ ក្នុងខែសីហា ឆ្នាំ២០០៥ ។ ករណីនេះត្រូវបានចងក្រងបានល្អ និងបានកត់សំគាល់ទាំងស្រុងថា មានភាពមិនប្រក្រតីធ្ងន់ធ្ងរ ។ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ បានបន្តយុទ្ធនាការយ៉ាងសកម្ម ដើម្បីឱ្យដោះលែងជនទាំងពីរនាក់នេះ ដោយសំអាងលើហេតុផលថា ពួកគេជាជនស្លូតត្រង់ ។

២៤. លោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេធ្វើឃាតនៅឯតូបលក់កាសែតមួយ ដែលគាត់តែងតែទៅទីនោះ នៅកណ្តាលទីក្រុងភ្នំពេញ នាព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ ។ ប៊ិន សំណាង និង សុខ សំអឿន ត្រូវបានចាប់ខ្លួនបួនថ្ងៃបន្ទាប់មក ។ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤ ចៅក្រមស៊ើបអង្កេតបានបញ្ជាឱ្យដោះលែងជនទាំងពីរនាក់នេះ ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់ ។ ព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍នឹងបញ្ជានេះ ។ វិធានការខាងវិន័យ ត្រូវបានគេចាត់ឡើងប្រឆាំងនឹងចៅក្រមរូបនេះ ដោយផ្អែកលើមូលហេតុផ្សេង ហើយពីរបីខែក្រោយមក គាត់ត្រូវបានគេផ្លាស់ទៅធ្វើការនៅតុលាការខេត្តមួយដាច់ស្រយ៉ាល ។ សាលាឧទ្ធរណ៍បានគាំទ្របណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ហើយបានបញ្ជូនករណីនេះត្រឡប់មកតុលាការក្រុងភ្នំពេញវិញ ដើម្បីបន្តការស៊ើបអង្កេតទៅទៀត ។ នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៥ ជនជាប់ចោទទាំងពីរនេះត្រូវបានតុលាការជំនុំជំរះ និងកាត់ទោស បន្ទាប់ពីសវនាការមួយដែលមិនបានបំពេញតាមបទដ្ឋាននៃការជំនុំជំរះប្រកបដោយភាពត្រឹមត្រូវ ហើយត្រូវបានទទួលការរិះយ៉ាងច្រើន ។ ពួកគេបានប្តឹងឧទ្ធរណ៍ក្នុងខែតុលា ឆ្នាំ២០០៥ ។ ភស្តុតាងថ្មីបានលេចចេញជាពន្លឺក្នុងខែកញ្ញា ឆ្នាំ២០០៦ នៅពេលដែលសាក្សីសំខាន់ម្នាក់នៃឃាតកម្មនេះ គឺម្ចាស់តូបលក់កាសែត បានឆ្លើយបំភ្លឺដោយផ្ទាល់មាត់ ប្រាប់ការិយាល័យសិទ្ធិមនុស្សOHCHR ថ្នាក់តំបន់នៅទីក្រុងបាងកក នៅមុនការតាំងលំនៅថ្មីនៅប្រទេសមួយទៀត ។ នៅក្នុងសេចក្តីបំភ្លឺនោះ គាត់បានរៀបរាប់លំអិតអំពីមនុស្សម្នាក់ដែលបានបាញ់សម្លាប់លោក ជា វិជ្ជា ហើយថាគាត់មិនបានឃើញទណ្ឌិតណាម្នាក់ក្នុងចំណោមទណ្ឌិតទាំងពីរនាក់នេះនៅទីនោះទេ ។ ការិយាល័យបានបញ្ជូនសេចក្តីបំភ្លឺនេះទៅអាជ្ញាធរពាក់ព័ន្ធ ។ សាលាឧទ្ធរណ៍បានបើកសវនាការនៅថ្ងៃទី៦ ខែតុលា ដើម្បីសំរេចបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអ្នកទោសទាំងពីរនាក់នេះ មេធាវី សមាជិកគ្រួសារ សាក្សីចុងចោទ និងអង្គការក្រៅរដ្ឋាភិបាលនានាដែលពាក់ព័ន្ធ ។ បុគ្គលិកការិយាល័យក៏មានវត្តមាននៅពេលនោះដែរ ។ ប៉ុន្តែរំពេចនោះ សាលាឧទ្ធរណ៍បានប្រកាសលើកពេលសវនា

ការ ដោយមូលហេតុចៅក្រមមួយរូបភ្លាមៗក៏ស្រាប់តែឈឺ ។ នៅក្នុងពេលធ្វើរបាយការណ៍នេះ កាលបរិច្ឆេទបើកសវនាការថ្មីមិនទាន់បានកំណត់នៅឡើយទេ ។

២៥. គ្រួសារលោក ជា វិជ្ជា និងអង្គការក្រៅរដ្ឋាភិបាលនានា បានបន្តធ្វើការអំពាវនាវសុំឱ្យស៊ើបអង្កេតករណីឃាតកម្មនេះ និងសុំឱ្យផ្តន្ទាទោសជនទាំងឡាយដែលទទួលខុសត្រូវ ។ ការិយាល័យប្រចាំកម្ពុជា តំណាងពិសេសមុនៗ និងតំណាងពិសេសបច្ចុប្បន្ន ក៏បានពាំនាំកង្វល់របស់ខ្លួនប្រាប់អាជ្ញាធរនានា ជាច្រើនលើកច្រើនសារដែរ ។ ករណីនេះកំពុងស្ថិតនៅចំពោះមុខគណៈកម្មាធិការសេរីភាពក្នុងការបង្កើតសមាគមនៃអង្គការពលកម្មអន្តរជាតិ បន្ទាប់ពីបានទទួលពាក្យបណ្តឹងក្នុងឆ្នាំ២០០៥ ពីសហព័ន្ធអន្តរជាតិនៃសហជីពសេរីកម្មករ ។

២៦. ករណីដទៃទៀត ដែលការិយាល័យបានទទួលដោះស្រាយ រួមមានករណីនៃការស្លាប់នៅក្នុងពន្ធនាគារខេត្តបាត់ដំបង ដែលមានអ្នកទោសយ៉ាងតិចប្រាំបីនាក់ និងឆ្មាំគុកម្នាក់ស្លាប់ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៦ នៅពេលដែលអ្នកទោសមួយក្រុម ក្នុងខណៈដែលកំពុងព្យាយាមរត់គេចខ្លួន បានចាប់ឆ្មាំគុកម្នាក់ធ្វើជាចំណាប់ខ្មាំង និងបានគំរាមធ្វើឱ្យផ្ទុះគ្រាប់បែកដៃមួយគ្រាប់ ។ ព្រឹត្តិការណ៍នោះត្រូវបានថតជាខ្សែវីដេអូ ហើយដែលក្រោយមកត្រូវបានចាក់ផ្សាយជាសាធារណៈ ។ ខ្សែវីដេអូបង្ហាញពីកំលាំងសន្តិសុខ កំពុងបាញ់ប្រហារទៅលើក្រុមអ្នកទោស និងចំណាប់ខ្មាំង ។ ការិយាល័យបានទំនាក់ទំនងអំពីកង្វល់របស់ខ្លួនប្រាប់ក្រសួងមហាផ្ទៃ ដោយគូសបញ្ជាក់អំពីការទទួលខុសត្រូវរបស់រដ្ឋាភិបាល ក្នុងការដឹកនាំការស៊ើបអង្កេតទាំងស្រុង និងមិនលំអៀង ហើយធ្វើការផ្តន្ទាទោសជនទាំងឡាយណាដែលគេរកឃើញថាបានចូលរួម ឬបានបញ្ជាឱ្យប្រើប្រាស់កំលាំងលើសលុប ដែលបណ្តាលឱ្យមានមនុស្សរងរបួស និងបាត់បង់ជីវិត ។ ការិយាល័យបានស្នើឱ្យបង្កើតក្រុមស៊ើបអង្កេតឯករាជ្យមួយ ហើយបានស្នើឱ្យផ្តល់អត្ថបទចំលងមួយច្បាប់នៃរបាយការណ៍ស៊ើបអង្កេតដែលក្រសួងបានធ្វើឡើង ។

២៧. ការិយាល័យក៏មានកង្វល់ផងដែរ អំពីការគំរាមកំហែងប្រឆាំងនឹងមជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលការពារស្ត្រី និងកុមារពីអំពើហឹង្សាក្នុងគ្រួសារ និងការធ្វើអាជីវកម្មផ្លូវភេទ ។ ការគំរាមកំហែងនេះ មានប្រភពពីបណ្តាញក្រុមសេពសន្ថវៈជាមួយអនីតិជន(Paedophilia) ប្រតិកម្មតបទៅនឹងករណីនៃជនបរទេសមួយចំនួន ដែលមជ្ឈមណ្ឌលនេះបានទទួលដោះស្រាយ និងបានបញ្ជូនទៅតុលាការ ។

## ត. នីតិរដ្ឋ និងវិស័យយុត្តិធម៌

២៨. ការិយាល័យប្រចាំកម្ពុជា បានបន្តរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់វិស័យយុត្តិធម៌ ។ ការិយាល័យបានរក្សាវត្តមាននៅតុលាការក្រុងភ្នំពេញ និងបានបន្តសហការជាមួយសាលាឧទ្ធរណ៍ និងតុលាការកំពូល តុលាការខេត្តបាត់ដំបង តាមរយៈការិយាល័យថ្នាក់តំបន់របស់ខ្លួន ក៏ដូចជា ជាមួយតុលាការខេត្ត-ក្រុង ដទៃទៀតក្នុងករណីជាក់លាក់ ។ ការិយាល័យបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការក្នុងវិស័យយុត្តិធម៌ និងបានចូលរួមក្នុងដំណើរការពិគ្រោះយោបល់ជាផ្លូវការក្នុងការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ តាមរយៈក្រុមការងារបច្ចេកទេសកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

២៩. ការិយាល័យបានបន្តធ្វើការតស៊ូមតិ ដើម្បីការអនុម័ត និងការអនុវត្តន៍ច្បាប់សំខាន់ៗ ឱ្យស្របតាមរដ្ឋធម្មនុញ្ញ និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដោយផ្តោតលើច្បាប់ទាំងឡាយដែលទាក់ទងផ្ទាល់ទៅនឹងអាណត្តិ និងអាទិភាពរបស់ខ្លួន ។ ក្នុងនោះមានច្បាប់ចំនួនប្រាំបី ដែលរដ្ឋាភិបាលបានយល់ព្រមផ្តល់អាទិភាព គឺ :

- ក្រមព្រហ្មទណ្ឌ

- ក្រមនីតិវិធីព្រហ្មទណ្ឌ

- ក្រមរដ្ឋប្បវេណី

- ក្រមនីតិវិធីរដ្ឋប្បវេណី

- ច្បាប់រៀបចំអង្គការ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ (ដើម្បីបង្កើតរចនាសម្ព័ន្ធជាមូលដ្ឋានសំរាប់ប្រព័ន្ធតុលាការ កំណត់សមត្ថកិច្ចរបស់តុលាការនីមួយៗ និងបង្កើតនីតិវិធីជាមូលដ្ឋាសំរាប់ការប្រព្រឹត្តទៅរបស់តុលាការ) ។

- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា

- វិសោធនកម្មច្បាប់ស្តីពីការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- ច្បាប់ប្រឆាំងអំពើពុករលួយ

៣០. សន្ទស្សន៍មួយត្រូវបានសំរេច នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ នៅពេលដែលក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានប្រកាសឱ្យប្រើ ។ ក្រមនេះនឹងចូលជាធរមាននៅក្នុងខែកក្កដា ឆ្នាំ២០០៧ បន្ទាប់ពីមានការពន្យាពេលសំរាប់ការបណ្តុះបណ្តាល និងការធ្វើឱ្យធ្លាប់ ។ ក្រមរដ្ឋប្បវេណីត្រូវបានបញ្ជូនទៅរដ្ឋសភាក្នុងខែធ្នូកន្លងមកនេះ ។ គណៈរដ្ឋមន្ត្រីបានអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌក្នុងខែសីហា ហើយបានបញ្ជូនក្រមនេះទៅរដ្ឋសភាក្នុងខែកញ្ញា ប៉ុន្តែមិនមានការរីកចំរើនទេ ចាប់ពីពេលធ្វើរបាយការណ៍នេះ ហើយការសង្ឃឹមថាក្រមនេះនឹងត្រូវបានអនុម័តទាន់ពេលសំរាប់ការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមនោះ គឺមិនទាន់ដឹងប្រាកដនៅឡើយទេ ។ មានការរីកចំរើនតិចតួច ក្នុងការអនុម័តច្បាប់ដែលនៅសេសសល់ បើទោះជាមានការរាយការណ៍ថា នឹងមានការជជែកពិភាក្សាច្រើនក៏ដោយ ។

៣១. ការិយាល័យបានតាមដានច្បាប់ប្រឆាំងអំពើពុករលួយ ដែលរដ្ឋាភិបាលបានយល់ព្រមថានឹងអនុម័តនៅក្នុងខែមិថុនា ឆ្នាំ២០០៦ ។ ទន្ទឹងនឹងមានការកែលំអរខ្លះនោះ សេចក្តីព្រៀងច្បាប់ដែលមានស្រាប់មានចំណុចខ្វះខាតច្រើន រួមទាំងការចែងអំពីស្ថាប័នប្រឆាំងអំពើពុករលួយ ដែលបានកំណត់ក្នុងច្បាប់ថាមានអាណត្តិស្វយ័តក្នុងការស៊ើបអង្កេត និងផ្តល់អភ័យឯកសិទ្ធិរួចផុតពីការចោទប្រកាន់ពីបទរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ចំពោះការលាតត្រដាងអំពើពុករលួយ ។ ការិយាល័យបានបន្តស៊ូមតិសំរាប់ការចូលជាសមាជិករបស់កម្ពុជាក្នុងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ។

៣២. ការិយាល័យក៏បានស្វែងរក ដើម្បីលើកកំពស់ការប្រកាន់ខ្ជាប់បទដ្ឋានសន្ធិសញ្ញាអន្តរជាតិ ក្នុងការព្រៀងច្បាប់ថ្មី ។ ឧទាហរណ៍ ការិយាល័យបានផ្តល់ការណែនាំដល់ក្រសួងមហាផ្ទៃ និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការព្រៀងច្បាប់ថ្មីស្តីពីបាតុកម្ម ដើម្បីធានាថាច្បាប់នេះជួយសំរួល ច្រើនជាងការរិតត្បិត ការប្រើប្រាស់សិទ្ធិសេរីភាពក្នុងការប្រជុំដោយសន្តិវិធី ។ តាមរយៈសេចក្តីព្រៀងច្បាប់ផ្សេងៗ រដ្ឋាភិបាលបានចាប់ផ្តើមទទួលយក ជាគោលការណ៍ នូវក្របខ័ណ្ឌច្បាប់មួយសំរាប់ការប្រមូលផ្តុំជាសាធារណៈ ដោយផ្អែកលើការជូនដំណឹង ជាជាងការសុំការអនុញ្ញាត ។

៣៣. ការិយាល័យបានទទួលធ្វើការងារទាក់ទងនឹងករណីក្នុងតុលាការ រួមទាំងករណីមួយចំនួនពាក់ព័ន្ធនឹងសកម្មជនសហគមន៍នៅក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្ត-ក្រុងនានា ដែលធ្វើការតវ៉ាប្រឆាំងនឹងការដណ្តើមយកដីធ្លី និងការជម្លៀសចេញដោយបង្ខំ ។ ការិយាល័យបានសង្កេតមើលការជំនុំជំរះមួយចំនួន និងសវនាការក្នុងតុលាការក្នុងករណីរឿងដែលពាក់ព័ន្ធ ។ ភាពមិនប្រក្រតីធ្ងន់ធ្ងរ ត្រូវបានកត់ត្រានៅក្នុងករណីភាគច្រើន ហើយមធ្យោបាយក្នុងការដោះស្រាយ និងការពង្រឹងសិទ្ធិដែលបានធានាការពារក្នុងច្បាប់ និងរដ្ឋធម្មនុញ្ញនៅមានកំរិតនៅឡើយ ។

៣៤. ការិយាល័យបានបន្តធ្វើការឃ្លាំមើលកិច្ចដំណើរការនៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) ដែលបានបង្កើតឡើង ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចៅក្រមជាតិ និងចៅក្រមអន្តរជាតិនៃអង្គជំនុំជំរះនេះ បានធ្វើសច្ចាប្រណិធាននៅដើមខែកក្កដា ក្នុងខណៈពេលដែលសហព្រះរាជអាជ្ញាក៏បានចូលកាន់តំណែង ហើយបានចាប់ផ្តើមធ្វើការស៊ើបអង្កេតបឋមរបស់ខ្លួនដែរ ។ សហចៅក្រមស៊ើបអង្កេតបានចាប់ផ្តើមការងាររបស់ខ្លួនក្នុងខែកញ្ញា ពាក់ព័ន្ធជាសំខាន់ ក្នុងការព្រៀងបទបញ្ជាផ្ទៃក្នុងរបស់អង្គជំនុំជំរះនេះ ។ ចៅក្រមទាំងអស់បានប្រជុំពេញអង្គក្នុងខែវិច្ឆិកា ដើម្បីពិភាក្សា និងអនុម័តបទបញ្ជាផ្ទៃក្នុងទាំងនេះ ដែលមានសារៈសំខាន់ក្នុងការធានាភាពត្រឹមត្រូវ និងភាពសុច្ចរិតនៃការជំនុំជំរះក្តី ។ ដូចបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍រួម ដែលបានចុះផ្សាយនៅថ្ងៃទី២៥ ខែវិច្ឆិកា នៅចុងសម័យប្រជុំពេញអង្គ ដោយមន្ត្រីតុលាការជាតិ និងអន្តរជាតិនៃអង្គជំនុំជំរះវិសាមញ្ញ(ECCC) បទបញ្ជាផ្ទៃក្នុងចែងអំពីនីតិវិធីក្នុងការបង្ហាញភស្តុតាងនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការ ចាប់ពីការស៊ើបអង្កេតបឋមរហូតដល់ការស៊ើបអង្កេតដោយចៅក្រម រហូតដល់ការជំនុំជំរះ និងឡើងដល់ឧទ្ធរណ៍ ហើយបានកំណត់បន្ទាត់តួនាទីរបស់ភាគីទាំងអស់ សហព្រះរាជអាជ្ញា មេធាវីការពារក្តី និងជនរងគ្រោះ ។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីថ្លែងការណ៍បានរាយ-ការណ៍អំពីភាពមិនចុះសម្រុងគ្នាជាដុំកំភួនលើការដាក់បញ្ចូលច្បាប់កម្ពុជា និងបទដ្ឋានអន្តរជាតិ តួនាទីរបស់អង្គភាពគាំទ្រមេធាវី រួមទាំងបញ្ហាស្តីពីគុណសម្បត្តិរបស់មេធាវី តុលាការ និងតួនាទីរបស់សហព្រះរាជអាជ្ញា និងផលប៉ះពាល់របស់វាទៅលើនីតិវិធីបោះឆ្នោត ។ មិនមានឱកាសដើម្បីលើកឡើងជាលំអិតអំពីបញ្ហាសំខាន់ៗដូចជាតួនាទីរបស់ជនរងគ្រោះ និងសិទ្ធិរបស់ភាគីរដ្ឋប្បវេណី ។ ជាលទ្ធផល សេចក្តីព្រៀងបទបញ្ជាផ្ទៃក្នុងមិនត្រូវបានអនុម័តទាំងស្រុង ឬសូម្បីតែមួយផ្នែកក៏ទេដែរ ។ កិច្ចដំណើរការជាផ្លូវការរបស់អង្គជំនុំជំរះនេះមិនអាចអនុវត្តបានទេ លុះត្រាតែបទបញ្ជាផ្ទៃក្នុងត្រូវបានអនុម័ត ។

៣៥. អនុលោមតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់សេចក្តីក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បទបញ្ជាផ្ទៃក្នុងត្រូវបានព្រៀងឡើងដោយផ្អែកលើច្បាប់កម្ពុជាស្តីពីនីតិវិធី (រួមទាំងសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយនៅពេលក្រមនេះត្រូវបានអនុម័ត វានឹងជំនួសឱ្យនីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្ន) ដោយមានការកែសំរួលត្រង់ចំណុចដែលខ្វះចន្លោះ ឬមិនច្បាស់លាស់ក្នុងច្បាប់កម្ពុជាស្តីពីនីតិវិធី ឬច្បាប់ដែលមានស្រាប់មិនស្របតាមបទដ្ឋានអន្តរជាតិ ។ ការពិភាក្សាលើកឡើងអំពីកង្វល់ពាក់ព័ន្ធនឹងបរិបទនៃសេចក្តីព្រៀងក្រម ។ ការិយាល័យនឹងបន្តតាមដានកិច្ចដំណើរការអនុម័តនេះយ៉ាងជិតដល់ ។

## ឃ. និទណ្ឌភាព

៣៦. ក្នុងខែតុលា ឆ្នាំ២០០៥ លោក **ភីទី លីយប្រេក** អតីតតំណាងពិសេសបានបញ្ចប់របាយការណ៍មួយ ដែលនិយាយអំពីទម្រង់ និងលំនាំនៃនិទណ្ឌភាព ដែលលោកតំណាងពិសេសបន្តបន្ទាប់មក និងអ្នកជំនាញការដទៃទៀត ធ្វើការក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ បានកត់ត្រាទុកចាប់តាំងពីដើមទសវត្សឆ្នាំ១៩៩០។ ការិយាល័យបានបកប្រែរបាយការណ៍នោះជាភាសាខ្មែរ ហើយបានបញ្ជូនទៅរដ្ឋាភិបាលក្នុងខែធ្នូ ឆ្នាំ២០០៥។ របាយ-ការណ៍នេះត្រូវបានផ្សព្វផ្សាយជាសាធារណៈក្នុងខែកុម្ភៈ ឆ្នាំ២០០៦។ របាយការណ៍នេះមានគោលបំណងជំរុញឱ្យមាន ការពិភាក្សាគ្នាអំពីចរិត និងផលប៉ះពាល់នៃនិទណ្ឌភាព និងការអនុម័តវិធានការនានា ដើម្បីបញ្ចប់បញ្ហានិទណ្ឌភាព។

៣៧. ការិយាល័យប្រចាំកម្ពុជា បានបន្តតាមដានករណីជាកង្វល់មួយចំនួនដែលមិនទាន់ដោះស្រាយ រួមមាន ករណីដែលបានបញ្ជាក់ក្នុងរបាយការណ៍នេះ។ ករណីរបស់លោក ជា វិជ្ជា ត្រូវបានរៀបរាប់រួចហើយ។ ករណីមួយទៀត គឺករណីលោក រស់ សុវណ្ណារ៉េត ជាសមាជិកគណៈកម្មការនាយកនៃសហជីពកម្មករដដែលនេះ ដែលនៅថ្ងៃទី៧ ខែ ឧសភា ឆ្នាំ២០០៤ ត្រូវបានគេបាញ់សំលាប់នៅក្រុងភ្នំពេញ។ ករណីរបស់គាត់ក៏កំពុងស្ថិតនៅចំពោះមុខគណៈកម្មាធិ-ការសេរីភាពខាងសមាគមនៃអង្គការពលកម្មអន្តរជាតិដែរ។ ទាហានកងទ័ពឆ័ត្រយោងមួយរូបអាយុ២២ ឆ្នាំ ដែលបាន បដិសេធពិរុទ្ធភាព ត្រូវបានផ្តន្ទាទោសពីបទឃាតកម្ម ក្នុងខែមីនា ឆ្នាំ២០០៥ ហើយត្រូវបានតុលាការកាត់ទោសដាក់ ពន្ធនាគាររយៈពេល១៥ ឆ្នាំ។ ការជំនុំជំរះនេះ ត្រូវបានគេកត់សំគាល់ថា បានរំលោភធ្ងន់ធ្ងរលើវិធានខាងនីតិវិធីនិង បទដ្ឋានគ្រឹះស្តីពីការជំនុំជំរះប្រកបដោយភាពត្រឹមត្រូវ។ ចុងចំលើយបានប្តឹងឧទ្ធរណ៍ភ្លាមបន្ទាប់ពីតុលាការប្រកាស សាលក្រម។ កាលបរិច្ឆេទសំរាប់សវនាការឧទ្ធរណ៍នៅមិនទាន់បានកំណត់នៅឡើយទេ។ ការិយាល័យបានទទួលដំណឹង ថា ការជំនុំជំរះត្រូវបានពន្យាពេល ដោយសារខ្វះចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។

៣៨. ការិយាល័យបានបន្តតាមដានការវិវត្តន៍នៃករណីដទៃទៀត ទាក់ទងនឹងការស៊ើបអង្កេតលសំលាប់ឥស្សរជន ជាន់ខ្ពស់ ដែលបានកើតឡើងនៅក្រុងភ្នំពេញ នៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ និងភាពទាល់ ច្រកខាងនយោបាយ ដែលបានអូសបន្លាយ នៅមុនការបង្កើតរដ្ឋាភិបាលថ្មីក្នុងខែកក្កដា ឆ្នាំ២០០៤។ ឥស្សរជនទាំងនោះ រួមមានព្រះតេជគុណ សម ប៊ុនធឿន នាយកមជ្ឈមណ្ឌលវិបស្សនា ជាព្រះសង្ឃ និងជាគ្រូបង្រៀនមួយរូប ដែលត្រូវគេ បាញ់សំលាប់នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៣ ដោយខ្មាន់កាំភ្លើងពីរនាក់ ហើយបានសុគត ២ ថ្ងៃបន្ទាប់មក។ មិនមាន ឃាតករណាម្នាក់ត្រូវបានចាប់ខ្លួននៅក្នុងឧក្រិដ្ឋកម្មនេះទេ។ លោក ឱម រ័ត្នសាឌី ទីប្រឹក្សាជាន់ខ្ពស់មួយរូបនៃគណៈ បក្សហ៊្វុនស៊ិនប៉ិច ត្រូវបានគេបាញ់សំលាប់នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៣ ហើយបានទទួលមរណភាពក្នុងថ្ងៃដដែល

នោះ ។ បន្ទាប់មកមិនយូរប៉ុន្មាន ជនពីរនាក់ត្រូវបានចាប់ខ្លួន ហើយបានសារភាពថាខ្លួនជាឃាតករ ដោយអះអាងថាជាការប្រព្រឹត្តដោយអចេតនា ហើយថាខ្លួនមានបំណងប្លន់យកទូរស័ព្ទដៃរបស់ជនរងគ្រោះ ។ តុលាការក្រុងភ្នំពេញបានកាត់ទោសជនទាំងពីរនាក់នេះដាក់ពន្ធនាគាររយៈពេល២០ ឆ្នាំ ពីបទកាន់កាប់អាវុធខុសច្បាប់ បទប្លន់ និងបទមនុស្សឃាតដោយចេតនា ក្នុងខែតុលា ឆ្នាំ២០០៣ ។ ករណីនេះបាននាំឱ្យមានកង្វល់ជាច្រើន រួមទាំងគុណភាពនៃការស៊ើបអង្កេត និងការជំនុំជំរះ អំពីថាតើជនសង្ស័យបានប្រព្រឹត្តបទល្មើសតែឯកឯង ឬគោលបំណងនៃការប្លន់យកទូរស័ព្ទដៃអាចជឿបានថា វាផ្ទុយនឹងការរៀបរាប់ដោយសាក្សីមើលឃើញផ្ទាល់ភ្នែក និងការរៀបរាប់ដទៃទៀត ។ លោក ជួរ ជេដ្ឋារិទ្ធិ ជាអ្នកសារព័ត៌មាននៃស្ថានីយវិទ្យុតាព្រហ្ម ដែលមាននិន្នាការនយោបាយខាងគណៈហ៊្វុនស៊ិនប៉ិច ត្រូវបានគេបាញ់ស្លាប់នៅព្រឹកថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៣ នៅពេលដែលគាត់បានមកដល់កន្លែងធ្វើការ ។ មិនមានជនល្មើសណាម្នាក់ត្រូវបានចាប់ខ្លួនទេ ។ ក្រសួងមហាផ្ទៃបាននិយាយថា ករណីនេះកំពុងស្ថិតក្នុងការស៊ើបអង្កេត ។ រយៈពេលបីថ្ងៃបន្ទាប់មក នៅព្រឹកថ្ងៃទី២១ ខែតុលា កញ្ញា ទូច ស្រីនិច ជាអ្នកចម្រៀងដ៏មានប្រជាប្រិយ៍មួយរូប ត្រូវបានគេបាញ់ក្នុងចំងាយយ៉ាងជិតចំនួនបីគ្រាប់ ។ ម្តាយរបស់នាងក៏ត្រូវគេបាញ់ដែរ បន្ទាប់មកបានស្លាប់នៅក្នុងមន្ទីរពេទ្យ ។ បើតាមសាក្សី ករណីនេះពាក់ព័ន្ធនឹងជនបួននាក់ ជិះម៉ូតូពីរគ្រឿង ។ កញ្ញា ទូច ស្រីនិច នៅមានជីវិតរស់នៅនៅឡើយ ប៉ុន្តែនាងត្រូវពិការ ។ នាងនឹងសមាជិកគ្រួសាររបស់នាងបានទៅរស់នៅឯសហរដ្ឋអាមេរិកក្នុងខែមករា ឆ្នាំ២០០៥ ។ មិនមានជនល្មើសណាម្នាក់ត្រូវបានចាប់ខ្លួនទេ ហើយនគរបាលមិនអាចកំណត់អត្តសញ្ញាណជនសង្ស័យឡើយ ។

៣៩. ករណីដែលជាកង្វល់ជាយូរមកហើយ ដែលនៅមិនទាន់បានដោះស្រាយនៅឡើយ ហើយដែលក្រសួងមហាផ្ទៃបានជូនដំណឹងមកការិយាល័យ នៅតែស្ថិតក្នុងការបន្តស៊ើបអង្កេតដដែល ក្នុងនោះរួមមានការវាយប្រហារដោយគ្រាប់បែកដៃប្រឆាំងភាគីស៊ីនសាន នៃគណបក្សប្រជាធិបតេយ្យសេរីព្រះពុទ្ធសាសនា នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៥ ការវាយប្រហារដោយគ្រាប់បែកដៃនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៧ ប្រឆាំងបាតុកម្មអហឹង្សាមួយនៅក្រុងភ្នំពេញ ដែលក្នុងនោះមានមនុស្សយ៉ាងតិច១៤នាក់ត្រូវបាត់បង់ជីវិត ហើយជាង១០០ នាក់ទៀតត្រូវរងរបួស និងករណីឃាតកម្មលើលោក ហូរ សុខ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាសមាជិកជាន់ខ្ពស់មួយរូបនៃគណបក្សហ៊្វុនស៊ិនប៉ិច ដែលត្រូវបានគេបាញ់ស្លាប់នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៩៧ នៅក្រសួងមហាផ្ទៃ បន្ទាប់ពីចាប់ខ្លួន ។

៤០. ការិយាល័យក៏បានបន្តតាមដានករណីលោក អ៊ុត អឿន កសិកររស់នៅខេត្តព្រៃវែង ដែលត្រូវបានចាប់ខ្លួន នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០១ ដោយសង្ស័យថាជាចោរលួចក្របី ហើយបានស្លាប់បីថ្ងៃបន្ទាប់ ក្រោយពីបានជាប់ឃុំឃាំងក្នុងស្ថានីយនគរបាលបីផ្សេងគ្នា ។ប្រពន្ធនិងកូនស្រីរបស់គាត់ ដែលបានឃើញគាត់មុននឹងស្លាប់បាននិយាយថា មានស្នាមជាំពាសពេញលើដងខ្លួន និងលើផ្ទៃមុខរបស់គាត់ គាត់បានបាក់ធ្មេញពីរ ហើយបានក្អួតឈាម ។ ការិយា-

ល័យបានស្នើឱ្យអគ្គនាយកនគរបាលជាតិធ្វើការស៊ើបអង្កេត។ របាយការណ៍ស៊ើបអង្កេតបានសន្និដ្ឋានថា គាត់ស្លាប់ដោយជម្ងឺឈឺក្រពះធ្ងន់ធ្ងរ ការក្អួត និង " ការកោសខ្យល់ " ខ្លាំងជ្រុល ការកោសខ្យល់គឺជាវិធីព្យាបាលជម្ងឺជាប្រពៃណីមួយ គេប្រើសេនកោសដែលបន្សល់ទុកស្នាមនៅលើស្បែក។ នៅពេលធ្វើការស៊ើបអង្កេតនោះ គេមិនបានជួបសំភាសជាមួយគ្រួសារជនរងគ្រោះទេ។ តុលាការខេត្តព្រៃវែងបានចោទប្រកាន់នគរបាលពីរនាក់ ពីបទធ្វើមនុស្សឃាតដោយចេតនា ក្នុងខែកុម្ភៈ ឆ្នាំ២០០២ ហើយម្នាក់ទៀត ក្នុងខែកក្កដា ឆ្នាំ២០០២។ ប៉ុន្តែ ចាប់ពីពេលនោះមក ការជំនុំជំរះត្រូវបានពន្យាពេលជាច្រើនដង។ ជនជាប់ចោទត្រូវបានផ្លាស់ទៅស្រុកផ្សេងទៀត ហើយអាចដើរហើរបានដោយសេរីរង់ចាំសវនាការ។ នៅពេលសរសេរបញ្ចប់របាយការណ៍នេះ ការិយាល័យបានទទួលដំណឹងថាតុលាការនឹងបើកសវនា ការករណីនោះ នៅចុងខែមករា ឆ្នាំ២០០៧។

## ង. ដីធ្លី និងការចិញ្ចឹមជីវិត

៤១. ការិយាល័យប្រចាំកម្ពុជាបានពិនិត្យអំពីកត្តាសំខាន់ៗ ដែលប៉ះពាល់ដល់សិទ្ធិប្រើប្រាស់ដីធ្លី និងប្រភពនៃការចិញ្ចឹមជីវិត ដោយផ្តោតលើការផ្តល់ និងផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច និងការផ្ទេរកម្មសិទ្ធិដីធ្លី ដែលជនជាតិភាគតិចកម្ពុជាបានប្រឈមមុខ។ ក្នុងការធ្វើបែបនេះ ការិយាល័យបានពិនិត្យច្បាប់ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធនិងការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លី រួមទាំងច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យនានាដែលពាក់ព័ន្ធ។ ការិយាល័យបានផ្តោតជាសំខាន់លើច្បាប់ និងបទបញ្ញាទាំងឡាយដែលទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច និងការចុះបញ្ជីដីជនជាតិដើមភាគតិច។

៤២. ការិយាល័យបានឃ្លាំមើលការផ្តល់សម្បទានដីសេដ្ឋកិច្ច ដើម្បីវាយតំលៃលើការអនុវត្តន៍តាមក្របខ័ណ្ឌ និងនីតិវិធីដែលបានកំណត់ និងផលប៉ះពាល់ទៅលើប្រជាពលរដ្ឋមូលដ្ឋាន។ ការិយាល័យមានកង្វល់អំពីផលប៉ះពាល់អវិជ្ជមាននៃសម្បទានដីសេដ្ឋកិច្ចទៅលើសហគមន៍មូលដ្ឋាន រួមមានការកាប់បំផ្លាញព្រៃឈើ ការបាត់បង់សិទ្ធិប្រើប្រាស់អនុផលព្រៃឈើ ការបាត់បង់វាលស្មៅសំរាប់ចិញ្ចឹមសត្វពាហណៈ និងការបាត់បង់ដីស្រែចំការដែលនាំឱ្យមានកង្វះស្បៀងអាហារ។ សហគមន៍នានាដែលទទួលរងផលប៉ះពាល់ក៏បានសំដែងការព្រួយបារម្ភផងដែរអំពីការមិនបានពិគ្រោះយោបល់ជាមួយពួកគេ មុននឹងផ្តល់សម្បទាន និងអំពីការដែលពួកគេទទួលរងការបំភិតបំភ័យ នៅពេលធ្វើការតស៊ូមតិដើម្បីទាមទារសិទ្ធិលើដីធ្លី។

៤៣. ជាឧទាហរណ៍ នៅស្រុកស្រែអំបិល ខេត្តកោះកុង អ្នកស្រុកដែលបានរស់នៅ និងបានធ្វើការដាំដុះលើដីនោះរយៈពេលជាង២៥ ឆ្នាំហើយ បានបាត់បង់ដីស្រែ និងផលដំណាំរបស់ខ្លួន ដោយសារសម្បទានដែលបានផ្តល់ទៅឱ្យក្រុមហ៊ុនមួយ ដែលមួយផ្នែកនៃសម្បទាននោះជារបស់សមាជិកព្រឹទ្ធសភាកម្ពុជាមួយរូប ។ ការផ្តល់សម្បទាននោះ មិនមានការពិគ្រោះយោបល់ជាសាធារណៈទេ វាផ្ទុយទៅនឹងសេចក្តីតម្រូវរបស់អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ហើយក្រុមហ៊ុនបានចាប់ផ្តើមឈូសឆាយដី នៅមុនពេលចុះកិច្ចសន្យា ។ ក្នុងខែកញ្ញា ឆ្នាំ២០០៦ កំលាំងសន្តិសុខក្រុមហ៊ុនបានប្រើអំពើហឹង្សាប្រឆាំងនឹងអ្នកស្រុកដែលនាំគ្នាតវ៉ា  អង្គការក្រៅរដ្ឋាភិបាលនានាត្រូវបានហាមឃាត់មិនឱ្យចូលក្នុងតំបន់នោះ ហើយអ្នកស្រុកបានរាយការណ៍ថា គេបានប្រាប់ពួកគាត់មិនឱ្យជួបប្រជុំគ្នាលើសពីមួយម៉ោងឡើយ ព្រោះវាប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ។

៤៤. សម្បទានដីសេដ្ឋកិច្ចភាគច្រើន ដែលបានផ្តល់មិនបានគោរពតាមសេចក្តីតម្រូវ និងនីតិវិធីដែលបានកំណត់នៅក្នុងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចឡើយ ។ ករណីដែលជាកង្វល់បំផុតនោះគឺ ការមិនគិតគូរើពើចំពោះការអភិវឌ្ឍន៍សហគមន៍ដែលមានស្រាប់ និងការផ្តួចផ្តើមគំនិតគ្រប់គ្រងធនធានធម្មជាតិ ដូចជាការបង្កើតសហគមន៍ព្រៃឈើ និងការធ្វើផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម នៅមុនការផ្តល់សម្បទាន ។ ឧទាហរណ៍ នៅស្រុកសំរោង ខេត្តឧត្តរមានជ័យ សហគមន៍មូលដ្ឋានបាន និងកំពុងធ្វើការចរចាឱ្យបង្កើតសហគមន៍ព្រៃឈើមួយកន្លែងដែលមានផ្ទៃដី ២០០០ ហិកតា ដែលបច្ចុប្បន្នត្រូវបានគេសន្យាផ្តល់សម្បទានដីសេដ្ឋកិច្ច ។ ការិយាល័យក៏បានទទួលរបាយការណ៍អំពីការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានរ៉ែនៅលើតំបន់ការពារ និងដីដែលសហគមន៍ជនជាតិដើមភាគតិចកាន់កាប់ជាប្រពៃណី ។

៤៥. ការិយាល័យមានកង្វល់ថា ជនជាតិដើមភាគតិចកម្ពុជាកាន់តែរងគ្រោះខ្លាំងឡើងៗពីការបាត់បង់ដីធ្លីរបស់ខ្លួន តាមរយៈការដណ្តើមយកដីធ្លី ការលក់ដីដោយបង្ខំ ឬដោយខុសច្បាប់ និងការផ្តល់ការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀត ។ ការិយាល័យបានទទួលរបាយការណ៍ថា សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីដទៃទៀតជាច្រើន រួមទាំងសម្បទានរ៉ែ ត្រូវបានផ្តល់ ឬកំពុងធ្វើការពិចារណា នៅខេត្តមួយចំនួនភាគឦសាន ក្នុងតំបន់ដែលជនជាតិដើមភាគតិចកំពុងរស់នៅ ។ នៅក្នុងសេចក្តីថ្លែងការណ៍មួយដែលបានចុះផ្សាយនៅក្នុងឱកាសទិវាអន្តរជាតិសំរាប់ជនជាតិដើមភាគតិចពិភពលោក ៩ សីហា ២០០៦ ការិយាល័យបានរំលឹកអំពីការទទួលស្គាល់ជាអន្តរជាតិនៃសិទ្ធិជនជាតិដើមភាគតិចលើដីធ្លី និងធនធានធម្មជាតិ បានកត់សំគាល់អំពីបញ្ញត្តិនៃច្បាប់ភូមិបាល ដែលទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច លើកម្មសិទ្ធិដីសមូហភាព ហើយបានអំពាវនាវជាបន្ទាន់សុំឱ្យអនុម័តច្បាប់ និងវិធានការផ្សេងៗទៀត ដើម្បីការពារ និងអនុវត្តសិទ្ធិជនជាតិដើមភាគតិចលើដីធ្លី ។

៤៦. ការិយាល័យកំពុងធ្វើការជាមួយក្រុមប្រទេសអ្នកផ្តល់ជំនួយ អង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារអង្គការសហប្រជាជាតិដទៃទៀត ដើម្បីរៀបចំសិក្ខាសាលាមួយស្តីពីជនជាតិដើមភាគតិច និងការប្រើប្រាស់ដីធ្លីក្នុងប្រទេសកម្ពុជា ដែលនឹងត្រូវប្រារព្ធធ្វើនៅក្នុងខែមីនា ឆ្នាំ២០០៧។ សិក្ខាសាលានេះនឹងអញ្ជើញតំណាងសហគមន៍ជនជាតិដើមភាគតិច ក្រសួង-ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ទីភ្នាក់សហប្រតិបត្តិការអភិវឌ្ឍន៍ និងទីភ្នាក់ងារអង្គការសហប្រជាជាតិនានា ដើម្បីពិនិត្យបញ្ហាសំខាន់ៗដែលជនជាតិដើមភាគតិចកម្ពុជាកំពុងជួបប្រទះទាក់ទងនឹងដីធ្លី នឹងលើកស្នើនូវវិធានការជាក់ស្តែងមួយចំនួន ដើម្បីអនុវត្ត និងការពារសិទ្ធិជនជាតិដើមភាគតិច។ ការិយាល័យនឹងធ្វើរបាយការណ៍ស្តីពីផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច ទៅលើសហគមន៍ជនជាតិដើមភាគតិច។

៤៧. ការិយាល័យបានបន្តឆ្លើយតបយ៉ាងប្រុងប្រយ័ត្នចំពោះជំលោះដីធ្លី និងធនធានធម្មជាតិនៅតំបន់ពាយព្យនៃកម្ពុជា ធ្វើការតាមរយៈការិយាល័យប្រចាំតំបន់របស់ខ្លួនក្នុងខេត្តបាត់ដំបង និងសហការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកនានា។ ជំលោះដែលមានលក្ខណៈស្មុគ្រស្មាញ រវាងអ្នកស្រុកក្រីក្រ និងអ្នកមានឥទ្ធិពល ឬចំណងសេដ្ឋកិច្ច និងនយោបាយខ្លាំង រួមមានមន្ត្រីយោធា និងអ្នកមានផលប្រយោជន៍ខាងពាណិជ្ជកម្ម។

៤៨. ការិយាល័យក៏បានបន្តតាមដានករណីពិសេសមួយចំនួន ដែលសកម្មជនសហគមន៍ និងអ្នកស្រុកពាក់ព័ន្ធនឹងជំលោះដីធ្លីជាមួយបុគ្គល ឬក្រុមហ៊ុនដែលមានអំណាច បានប្រឈមមុខនឹងការគំរាមកំហែង ឬបានក្លាយជាកម្មវត្ថុនៃបណ្តឹងព្រហ្មទណ្ឌ។ ចំនួនករណីកើនឡើងច្រើន ដែលបញ្ញត្តិព្រហ្មទណ្ឌនៃច្បាប់ភូមិបាល ជាពិសេស បញ្ញត្តិស្តីពីការរំលោភលើទ្រព្យសម្បត្តិឯកជន ត្រូវបានគេប្រើដើម្បីចាប់ខ្លួនតំណាងសហគមន៍ដែលពាក់ព័ន្ធនឹងជំលោះដីមិនទាន់ចុះបញ្ជី។ ឧទាហរណ៍ នៅស្រុកបវេល ខេត្តបាត់ដំបង តំណាងសហគមន៍បីនាក់ត្រូវបានចាប់ខ្លួន ហើយបច្ចុប្បន្ននេះកំពុងជាប់ឃុំឃាំងរងចាំសវនាការ ពាក់ព័ន្ធនឹងដីមិនទាន់ចុះបញ្ជី។ ដោយសារចំនួនករណីនេះកើនឡើងខ្លាំង សកម្មជនសហ-គមន៍តែងភ័យខ្លាចគេចាប់ខ្លួន នៅពេលដែលតុលាការកោះហៅទៅសាកសួរ ហើយបុគ្គលិកការិយាល័យបានអមដំណើរសកម្មជនសហគមន៍នោះទៅកាន់កន្លែងណាត់ជួបនៅតុលាការខេត្ត-ក្រុង។ ការិយាល័យកត់សំគាល់ថាបញ្ញត្តិព្រហ្ម-ទណ្ឌនៃច្បាប់ភូមិបាល ជាទូទៅមិនបានជំរុញឱ្យមានការការពារប្រជាពលរដ្ឋ ដែលត្រូវក្រុមហ៊ុន និងអ្នកមានអំណាចមួយចំនួនរំលោភយកដីរបស់ខ្លួនឡើយ។

៤៩. ការិយាល័យបានធ្វើការទាក់ទងជាមួយប្រទេសអ្នកផ្តល់ជំនួយក្នុងវិស័យនៃការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ និងបានចូលរួមក្នុងក្រុមការងារបច្ចេកទេសដីធ្លី។ ការិយាល័យក៏បានបន្តធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាល និងបណ្តាញសង្គមស៊ីវិល ដោយផ្តោតលើការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ។

៥០. គំរោងផ្តល់មូលនីធិតូចៗចំនួនបួន ដែលបានជ្រើសរើសក្នុងឆ្នាំ២០០៤ តាមរយៈការជួយសហគមន៍ទាំងអស់គ្នា ជាគំរោងទូទៅមួយរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងភាពជាដៃគូជាមួយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ត្រូវបានបញ្ចប់ ។ គំរោងទាំងនេះបានជួយគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការតស៊ូមតិ ដើម្បីសិទ្ធិខាងបរិស្ថាន បណ្តុះបណ្តាលអំពីច្បាប់ គោលនយោបាយ និងការតស៊ូមតិ ដើម្បីជនជាតិដើមភាគតិច ច្បាប់ព្រៃឈើ និងការប្រើប្រាស់ធនធានព្រៃឈើ និងការបណ្តុះបណ្តាលដល់សហគមន៍នៃសាទនានា អំពីធនធានធម្មជាតិ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការតស៊ូមតិដើម្បីសិទ្ធិមនុស្ស ។

## ច.	ការប្រកាន់ខ្ជាប់នូវសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

៥១. ប្រទេសកម្ពុជាគឺជាភាគីមួយនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗមួយចំនួន លើកលែងតែអនុ-សញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ ។ កម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមចំនួនពីរ លើអនុសញ្ញាស្តីពីសិទ្ធិកុមារ ប៉ុន្តែមិនបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីពីរទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទេ បើទោះជារដ្ឋធម្មនុញ្ញនៃប្រទេសនេះលុបទោសប្រហារជីវិតហើយក៏ដោយ ។

៥២. ក្នុងខែវិច្ឆិកាកន្លងមកនេះ រដ្ឋសភាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលប្រទេសកម្ពុជាបានចុះហត្ថលេខាក្នុងខែកញ្ញា ឆ្នាំ២០០៥ ។ ការិយាល័យបានពិនិត្យភ្លាមៗនូវអត្ថបទជាភាសារខ្មែរដែលបានភ្ជាប់ជាមួយច្បាប់ និងបានធ្វើការណែនាំដល់ស្ថាប័នពាក់ព័ន្ធអំពីការកែតម្រូវអត្ថបទដែលបានបកប្រែខុស ។ ការិយាល័យបានរៀបចំការពិភាក្សាលើកដំបូងជាមួយសមភាគីរដ្ឋាភិបាលអំពីជំនួយបច្ចេកទេសដែលអាចមាន ដើម្បីបញ្ចប់កិច្ចដំណើរការផ្តល់សច្ចាប័ន និងដើម្បីគាំទ្រដល់ការអនុវត្តន៍ពិធីសារបន្ថែម ។

៥៣. កម្ពុជាមិនទាន់បានទទួលយកនីតិវិធីស្តីពីបណ្តឹងជាបុគ្គល ដែលមានចែងក្រោមសន្ធិសញ្ញានានាដែលកម្ពុជាជាភាគី ។ កម្ពុជាបានចុះហត្ថលេខាលើពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទក្នុងឆ្នាំ២០០១ និងពិធីសារបន្ថែមទីមួយទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក្នុងខែកញ្ញា ឆ្នាំ២០០៤ ប៉ុន្តែមិនទាន់ផ្តល់សច្ចាប័នលើលិខិតុបករណ៍ទាំងនេះនៅឡើយទេ ហើយក៏មិនទាន់

បានធ្វើការប្រកាសក្រោមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ឬមាត្រា២២ នៃអនុសញ្ញាប្រឆាំងទារុណកម្មដែរ ។

៥៤. កម្ពុជាមានកំណត់ហេតុចំរុះមួយស្តីពីការបំពេញកាតព្វកិច្ចធ្វើរបាយការណ៍សន្ធិសញ្ញារបស់ខ្លួន ។ ចាប់តាំងពីឆ្នាំ១៩៩២មក កម្ពុជាបានដាក់ស្នើ ហើយស្ថាប័នសន្ធិសញ្ញាបានធ្វើការពិចារណាលើរបាយការណ៍ចំនួន៦ ក្នុងចំណោមរបាយការណ៍ទាំងអស់២៣ ដែលបានតម្រូវក្រោមលក្ខខណ្ឌសន្ធិសញ្ញានានា ។ កម្ពុជាបានធ្វើរបាយការណ៍យ៉ាងតិចណាស់ក៏ម្តងដែរ ទៅស្ថាប័ននីមួយៗនៃស្ថាប័នសន្ធិសញ្ញាទាំងអស់ ។ បច្ចុប្បន្ននេះ មានរបាយការណ៍ចំនួន១២ បានហួសពេលកំណត់ ដែលក្នុងនោះ របាយការណ៍ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានហួសរយៈពេលកំណត់តាំងពីខែមិថុនា ឆ្នាំ១៩៩៤ ។ នៅក្នុងឆ្នាំ២០០៦ ការិយាល័យបានជួយបញ្ជូនរបាយការណ៍នេះ ដែលបានឈានដល់ដំណាក់កាលចុងក្រោយនៃការបញ្ចប់ជំនួយបច្ចេកទេសពីការិយាល័យ និងមានការចូលរួមពីទីភ្នាក់ងារសហប្រជាជាតិនានា នៅពេលដែលកិច្ចដំណើរការនេះត្រូវបានជាប់ឃាំងក្នុងខែមីនា ឆ្នាំ២០០៥ ។ សេចក្តីព្រាងរបាយ-ការណ៍តាមកាលកំណត់របស់កម្ពុជា ទៅគណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ត្រូវបានដាក់ស្នើទៅគណៈរដ្ឋមន្ត្រីក្នុងខែតុលា ឆ្នាំ២០០៦ ។

៥៥. ការិយាល័យបានជួយក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី និងមូលនីធិអភិវឌ្ឍន៍សហប្រជាជាតិសំរាប់ស្ត្រី ក្នុងការតាមដានសេចក្តីសង្កេត និងអនុសាសន៍ចុងក្រោយរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដែលត្រូវបានចុះផ្សាយក្នុងមករា ឆ្នាំ២០០៦ ។ កិច្ចខិតខំប្រឹងប្រែងរបស់ការិយាល័យបានផ្តោតលើការបណ្តុះបណ្តាលអំពីប្រព័ន្ធសន្ធិសញ្ញា និងការជួយដល់វិស័យទាំងអស់នៃរដ្ឋាភិបាលអនុវត្តអនុសាសន៍ ដោយមានការជួយគាំទ្របន្ថែមទៀតពីក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា ។

៥៦. មូលនីធិសហប្រជាជាតិសំរាប់កុមារ(UNICEF) បាននិងកំពុងជួយរៀបចំរបាយការណ៍តាមកាលកំណត់លើកទីពីររបស់កម្ពុជា ក្រោមអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានដល់ពេលកំណត់ក្នុងឆ្នាំ១៩៩៩ ។ ការិយាល័យបានចូលរួមក្នុងសិក្ខាសាលាមួយ ដែលបានរៀបចំឡើងដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ ដើម្បីពិភាក្សាអំពីសេចក្តីព្រាងរបាយការណ៍ជាមួយសង្គមស៊ីវិល ។

## ឆ.   ស្ថាប័នសិទ្ធិមនុស្សជាតិ

៥៧. ការិយាល័យនៅកម្ពុជាបានចូលរួមក្នុងសន្និបាតមួយស្ដីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិនៅកម្ពុជាក្នុងខែកញ្ញា ដែលបានរួមគ្នារៀបចំដោយគណៈកម្មាធិការសិទ្ធិមនុស្សរដ្ឋាភិបាល និងក្រុមការងារអង្គការក្រៅរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតយន្តការសិទ្ធិមនុស្សអាស៊ាន ។ នាយករដ្ឋមន្ត្រីបានបើកសិក្ខាសាលា និងបានអនុម័តយល់ព្រមលើការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ ស្របតាមគោលការណ៍ស្ដីពីស្ថាប័នជាតិសំរាប់លើកការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ដែលជាទូទៅគេស្គាល់ថាជា " គោលការណ៍ក្រុងប៉ារីស " ។ នាយករដ្ឋមន្ត្រីបានបញ្ជាក់ថា ការបង្កើតស្ថាប័ននេះមិនមានគោលបំណង ដើម្បីដាក់ជំនួយស្ថាប័នសិទ្ធិមនុស្សទាំងឡាយដែលមានស្រាប់នោះឡើយ ។ សន្និបាតបានព្រមព្រៀងបង្កើតក្រុមការងារចំរុះមួយ ដែលមានសមាសភាពតំណាងរដ្ឋាភិបាល និងតំណាងសង្គមស៊ីវិល ដែលទទួលខុសត្រូវលើការងារមួយចំនួន រួមទាំងការរៀបចំសេចក្ដីព្រាងច្បាប់ ដើម្បីបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ។

៥៨. នៅក្នុងសេចក្ដីថ្លែងការណ៍ទៅកាន់សន្និសីទ ការិយាល័យបានពន្យល់អំពីគោលការណ៍ទីក្រុងបារីសជាលំអិត ហើយបានគូសបញ្ជាក់ថា លើសពីបទដ្ឋានអប្បបរមាដែលបានកំណត់ ស្ថាប័នសិទ្ធិមនុស្សជាតិមួយដែលមានប្រសិទ្ធិភាព ទាមទារឱ្យមានបរិយាកាសគាំទ្រច្រើន ដើម្បីធ្វើការមានប្រសិទ្ធិភាព ។ ត្រូវតែមានឆន្ទះនយោបាយក្នុងជួររដ្ឋាភិបាល ប្រព័ន្ធតុលាការមួយដែលឯករាជ្យ និងមានប្រសិទ្ធភាព និងស្ថាប័នប្រជាធិបតេយ្យដទៃទៀត ការចូលរួមពីសង្គមស៊ីវិល និងវិទយិតភាពនៃការិយាល័យធិបតេយ្យ កំលាំងយោធា និងនគរបាល ។

៥៩. ស្ថាប័នសិទ្ធិមនុស្សជាតិមួយដែលមានប្រសិទ្ធភាព និងអាចជឿទុកចិត្តបាន ក៏ទាមទារឱ្យមានការយល់ដឹង និងការទទួលយកជាទូទៅនូវអាណត្តិតែមួយគត់របស់ខ្លួន ចំពោះរដ្ឋាភិបាល នីតិប្រតិបត្តិ តុលាការ និងអង្គការសង្គមស៊ីវិលនានា ទាំងអស់នេះគឺជាផ្នែកនៃប្រព័ន្ធជាតិមួយដែលមានតួនាទីការពារ និងលើកស្ទួយសិទ្ធិមនុស្ស ។ ការិយាល័យយល់ថា សេចក្ដីស្នើច្បាប់ដើម្បីបង្កើតស្ថាប័នមួយដូចនេះ ត្រូវតែឈរលើមតិភាគច្រើនក្នុងសង្គមកម្ពុជា ដោយមានការចូលរួមយ៉ាងពេញលេញពីសង្គមស៊ីវិល និងរដ្ឋាភិបាលក្នុងកិច្ចដំណើរការព្រៀងច្បាប់ ។

## ជ. កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល ជាមួយក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា

៦០. ការិយាល័យប្រចាំកម្ពុជាគឺជាសមាជិកមួយនៃក្រុមអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ដែលមានតួនាទីធ្វើសមាហរណកម្មសិទ្ធិមនុស្សឱ្យបានពេញលេញថែមទៀតទៅក្នុងការវិភាគ និងការធ្វើផែនការនៅកំរិតប្រទេស និងដើម្បីអនុវត្តបទដ្ឋានសិទ្ធិមនុស្សក្នុងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ជាតិ។ ការិយាល័យបានរួមចំណែកក្នុងការអនុវត្តវិស័យពាក់ព័ន្ធនៃក្របខណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ រួមទាំងការការពារសិទ្ធិមនុស្ស បង្កើនការចូលរួមរបស់សង្គមស៊ីវិលក្នុងការអភិវឌ្ឍន៍ និងការអនុវត្តន៍ និងការឃ្លាំមើលគោលនយោបាយសាធារណៈ ជួយឱ្យសាធារណៈជនទទួលបានព័ត៌មានច្រើនថែមទៀត និងការលើកកំពស់ប្រព័ន្ធយុត្តិធម៌មួយដែលឯករាជ្យ និងមានប្រសិទ្ធភាព។

៦១. ការិយាល័យបានចូលរួមក្នុងការប្រជុំយ៉ាងទៀតទាត់ ជាមួយក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា រួមទាំង ការប្រជុំប្រធានទីភ្នាក់ងារ និងការប្រជុំក្រុមប្រឹក្សាយោបល់គោលដៅអភិវឌ្ឍន៍សហសវត្ស ដែលមានការទទួលខុសត្រូវផងដែរចំពោះសិទ្ធិមនុស្ស។ ការិយាល័យបានធ្វើការជាមួយទីភ្នាក់ងារនីមួយៗ លើបញ្ហាដែលជាកង្វល់រួម ឧទាហរណ៍ ជាមួយអង្គការពលកម្មអន្តរជាតិ(ILO) លើបញ្ហាទាំងឡាយដែលទាក់ទងនឹងជនជាតិដើមភាគតិច និងជាមួយមូលនិធិសហប្រជាជាតិដើម្បីស្ត្រី(UNIFEM) និងមូលនិធិសហប្រជាជាតិដើម្បីកុមារ(UNICEF) លើការធ្វើរបាយការណ៍ និងការតាមដានសន្ធិសញ្ញា។

៦២. ការិយាល័យក៏បានធ្វើការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគីនានាក្រៅប្រព័ន្ធអង្គការសហប្រជាជាតិ ដើម្បីជួយធ្វើសមាហរណកម្ម និងអនុវត្តបទដ្ឋានសិទ្ធិមនុស្សទៅក្នុងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍។ ការិយាល័យបានចូលរួមក្នុងកិច្ចដំណើរការនៃក្រុមពិគ្រោះយោបល់ ជាពិសេស នៅក្នុងក្រុមការងារបច្ចេកទេស២ ក្នុងចំណោមក្រុមការងារបច្ចេកទេសទាំង ៨ ( ស្ដីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងដីធ្លី) ដែលតម្រូវឱ្យមានការរៀបយុទ្ធសាស្ត្ររួម និងផែនការសកម្មភាពសំរាប់វិស័យនេះ និងដើម្បីឃ្លាំមើលការរីកចំរើនចំពោះសន្ទស្សន៍ឃ្លាំមើលរួម ដែលរដ្ឋាភិបាល និងប្រទេសអ្នកផ្ដល់ជំនួយបានព្រមព្រៀងគ្នារួចហើយ។

៦៣. ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិឆ្នាំ២០០៦ - ២០១០ សំរាប់ការអភិវឌ្ឍន៍ ការងារ សមភាព និងប្រសិទ្ធភាព ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍កម្ពុជា ត្រូវបានចេញផ្សាយនៅពាក់កណ្ដាលខែកុម្ភៈ ឆ្នាំ២០០៦ ជាផែន

ការមេសំរាប់អភិវឌ្ឍន៍កម្ពុជា ។ ការិយាល័យបានធ្វើការតស៊ូមតិ ដើម្បីឱ្យមានការប្តេជ្ញាចិត្តច្បាស់លាស់ខាងសិទ្ធិមនុស្ស នៅក្នុងផែនការនេះ រួមទាំងការផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ អនុសញ្ញាអង្គការពលកម្មអន្តរជាតិស្តីពីជនជាតិដើមភាគតិច និងពួកកុលសម្ព័ន្ធ (លេខ ១៦៩) និងនីតិវិធីស្តីពីបណ្តឹងបុគ្គលដែលមានចែងក្រោមសន្ធិសញ្ញាទាំងនេះ ដែលកម្ពុជាគឺជាភាគីមួយ ។ ការិយាល័យបានបន្តស្នើឱ្យបញ្ជាក់ក្នុងផែនការនេះ អំពីគោលបំណងលើកកំពស់ការគោរព និងការទទួលបាននូវសិទ្ធិមនុស្ស និងសេរីភាពសំរាប់មនុស្សគ្រប់រូប ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិ ។ អត្ថបទចុងក្រោយនៃគំរោងនេះ ចែងយោងអំពីសិទ្ធិមនុស្សថាជាផ្នែកមួយនៃក្របខណ្ឌអភិបាលកិច្ចទូទៅ ចាំបាច់សំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។

## ឈ. កម្មវិធីអប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយព័ត៌មានសាធារណៈ

៦៤. ការិយាល័យប្រចាំកម្ពុជាបានបន្តលើកកំពស់ការយល់ដឹងអំពីបទដ្ឋាន និងយន្តការសិទ្ធិមនុស្សអន្តរជាតិ និងការអនុវត្តន៍បទដ្ឋាន និងយន្តការទាំងនេះនៅក្នុងស្រុក ហើយដើម្បីបង្កបរិយាកាសងាយស្រួលសំរាប់ការងារសិទ្ធិមនុស្ស និងការយល់ដឹងថែមទៀតអំពីតួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល ដែលការពារ និងតស៊ូមតិដើម្បីសិទ្ធិមនុស្ស ។

៦៥. ការិយាល័យបានជួយសំរួលដល់ការចូលរួមរបស់លោកស្រី ហ៊ីណា ជីឡានី តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសកម្មជនសិទ្ធិមនុស្ស នៅក្នុងឱកាសរំលឹកខួបទិវាសិទ្ធិមនុស្សក្នុងខែធ្នូ ។ តំណាងពិសេសបានចូលរួមក្នុងក្រុមពិភាក្សាអំពីសិទ្ធិមនុស្ស និងភាពក្រីក្រដែលបានរៀបចំឡើងដោយគណៈកម្មាធិការប្រព្រឹត្តកម្មសិទ្ធិមនុស្សកម្ពុជា ។ លោកស្រីបានថ្លែងសន្ទរកថា ទៅកាន់ក្រុមមនុស្សយ៉ាងច្រើនកុះករនៅពហុកីឡាដ្ឋានអូឡាំពិក ដែលបានរៀបចំឡើងដោយអង្គការប្រមាណជា៩០ អង្គការ ។ លោកស្រីបានធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា និងបានជួបប្រជុំជាមួយបុគ្គលិកនៃមជ្ឈមណ្ឌលនេះ ។ បន្ទាប់មក លោកស្រីបានជួបជាមួយអង្គការក្រៅរដ្ឋាភិបាល និងក្រុមមួយចំនួន ដែលធ្វើការដើម្បីសិទ្ធិមនុស្ស ច្បាប់ និងការអភិវឌ្ឍន៍ ដើម្បីពន្យល់អំពីអាណត្តិ និងចែករំលែកបទពិសោធន៍របស់លោកស្រី ។ លោកស្រីក៏បានជួបជាមួយតំណាងក្រុមអង្គការសហប្រជាជាតិប្រចាំកម្ពុជា ប្រទេសអ្នកផ្តល់ជំនួយទ្វេរភាគី សហគមន៍ការទូត និងអ្នកសារព័ត៌មាននានា ។

៦៦. ក្រៅពីកម្មវិធីបោះពុម្ពផ្សាយការបកប្រែថ្មីជាភាសាខ្មែរនូវសន្ធិសញ្ញាសំខាន់ៗស្តីពីសិទ្ធិមនុស្ស ការិយា-ល័យ និងមូលនិធិសហប្រជាជាតិ ដើម្បីកុមារ(UNICEF) បានរួមគ្នាបោះពុម្ពផ្សាយអត្ថបទបកប្រែដែលបានពិនិត្យកែ

សំរួលឡើងវិញនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបានសំរបសំរួលការងារជាមួយមូលនិធិអភិវឌ្ឍន៍សហប្រជាជាតិ ដើម្បីស្ត្រី(UNIFEM)ក្នុងការបោះពុម្ពផ្សាយអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ ។ ការបោះពុម្ពផ្សាយរបស់ការិយាល័យនូវអត្ថបទបកប្រែដែលបានពិនិត្យកែសំរួលឡើងវិញនៃធម្មនុញ្ញអន្តរជាតិស្តីពីសិទ្ធិមនុស្សត្រូវបានបោះពុម្ពឡើងវិញ ។ ការិយាល័យបានចុះផ្សាយ និងបានចែកចាយអត្ថបទថ្មីនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស សេចក្តីប្រកាសស្តីពីសកម្មជនសិទ្ធិមនុស្ស និងគោលការណ៍ស្តីពីការបង្កើតស្ថាប័នជាតិ ជាភាសាខ្មែរ និងភាសាអង់គ្លេស ។

៦៧. ការិយាល័យបានបន្តចែកចាយនៅទូទាំងប្រទេសកម្ពុជា នូវកម្រងឯកសារច្បាប់ជាភាសាខ្មែរ ដែលបានបោះពុម្ពលើកទីបួន ដែលការិយាល័យបានបោះពុម្ពផ្សាយក្នុងខែកញ្ញា ឆ្នាំ២០០៥ ។ សេចក្តីត្រូវការកម្រងឯកសារច្បាប់នៅតែខ្លាំងជាដដែល ដោយសារការស្វែងរកអត្ថបទច្បាប់នៅមានការលំបាកនៅឡើយ ។ កម្រងឯកសារនេះ បច្ចុប្បន្នអាចរកបានផងដែរ នៅលើវិបសាយរបស់ការិយាល័យ ដែលនឹងត្រូវរៀបចំឱ្យមាន ដើម្បីងាយស្រួលក្នុងការធ្វើបច្ចុប្បន្នភាព និងបញ្ចូលបន្ថែម នៅពេលដែលច្បាប់ថ្មីៗត្រូវបានអនុម័ត ។ នៅពេលដ៏ឆាប់ខាងមុខនេះ ការិយាល័យនឹងផ្តល់កម្រងឯកសារច្បាប់ក្នុងទម្រង់ជាស៊ីឌីរ៉ូម(CD-ROM) ដើម្បីឱ្យអ្នកប្រើប្រាស់កាន់តែងាយស្រួលរក និងរៀបចំឱ្យមានជាស្រេចសំរាប់អ្នកប្រតិបត្តិច្បាប់ និងអ្នកសិក្សាស្រាវជ្រាវអំពីច្បាប់បានទូលំទូលាយថែមទៀត ។

៦៨. វិបសាយរបស់ការិយាល័យត្រូវបានបង្កើត និងបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ។ វិបសាយនេះមានឯកសារសាធារណៈទាំងអស់ជាភាសាអង់គ្លេស និងជាភាសាខ្មែរ ដែលការិយាល័យ និងតំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាបានរៀបចំឡើង ក៏ដូចជាឯកសាររបស់អ្នករាយការណ៍ពិសេស និងឯកសាររបស់អង្គការសហប្រជាជាតិ និងស្ថាប័នសន្ធិសញ្ញា និងសេចក្តីសំរេចចិត្តទាំងឡាយពាក់ព័ន្ធនឹងកម្ពុជា ។

៦៩. ការិយាល័យបានបន្តបកប្រែជាភាសាខ្មែរ និងធ្វើការចែកចាយសៀវភៅ អត្ថបទច្បាប់ និងព័ត៌មានផ្សេងៗទៅក្រសួងនានារបស់រដ្ឋាភិបាល សាធារណៈជនទូទៅ អង្គការក្រៅរដ្ឋាភិបាល និស្សិត និងមន្ត្រីរដ្ឋាភិបាល ។

៧០. បុគ្គលិកការិយាល័យបានចូលរួមជាប្រចាំក្នុងសិក្ខាសាលា និងសិក្ខាសិក្សាផ្សេងៗ ដែលជារឿយៗបានដើរតួនាទីជាធនធានមនុស្ស ។ ក្នុងនោះមានសិក្ខាសាលាបណ្តុះបណ្តាលអង្គការក្រៅរដ្ឋាភិបាលនានា ទាក់ទងនឹងការប្រើប្រាស់ និងការយល់ដឹងអំពីយន្តការការពារសិទ្ធិមនុស្សអន្តរជាតិ វគ្គសិក្សារយៈពេលពីរថ្ងៃស្តីពីសិទ្ធិមនុស្សដល់និស្សិតមួយក្រុមនៅសាលាហ្វឹកហ្វឺនកងរាជអាវុធហត្ថជាតិកាំមូល និងវគ្គសិក្សារយៈពេលខ្លីជាមួយគណៈកម្មការសិទ្ធិមនុស្សព្រឹទ្ធសភា ដែលផ្តោតជាពិសេសលើតួនាទីរបស់សភាក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ។ បុគ្គលិកការិយា-

ល័យប្រចាំតំបន់បានចូលរួមក្នុងសិក្ខាសាលា និងសិក្ខាសិក្សាស្តីពីសិទ្ធិមនុស្ស បញ្ហាដីធ្លី និងការចិញ្ចឹមជីវិត ដែលបានរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរខេត្ត និងបានជួយរៀបចំទិវាសិទ្ធិមនុស្សនៅទីរួមខេត្តបាត់ដំបងក្រោមប្រធានបទសិទ្ធិមនុស្ស និងភាពក្រីក្រ ។ ការិយាល័យក៏បានចេញប្រកាសព័ត៌មានស្តីពីទិវាសិទ្ធិមនុស្ស ក្រោមប្រធានបទ " សិទ្ធិមនុស្ស និងភាពក្រីក្រ " ។

៧១. ការិយាល័យបានរាយការណ៍យ៉ាងទៀងទាត់ដល់អ្នកការទូតនានាប្រចាំកម្ពុជា និងអ្នកការទូតដែលមកធ្វើទស្សនកិច្ច អ្នកស្រាវជ្រាវ និងតំណាងអង្គការអន្តរជាតិនានា ។ ការិយាល័យបានទំនាក់ទំនងយ៉ាងទៀងទាត់ជាមួយប្រព័ន្ធសារព័ត៌មានផ្សេងៗ ។

៧២. ការិយាល័យបានរៀបចំយ៉ាងទៀងទាត់នូវរបាយការណ៍ប្រចាំខែ និងរបាយការណ៍ដទៃទៀតសំរាប់ទីស្នាក់ការការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំក្រុងហ្សឺណែវ ដើម្បីបំពេញសេចក្តីតម្រូវខាងរបាយការណ៍ ។

## V. កិច្ចការបុគ្គលិក និងរដ្ឋបាលរបស់ការិយាល័យឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

៧៣. ការិយាល័យប្រចាំកម្ពុជាបានអនុវត្តសកម្មភាពរបស់ខ្លួន តាមរយៈការិយាល័យធំរបស់ខ្លួននៅទីក្រុងភ្នំពេញ និងការិយាល័យតូចមួយថ្នាក់តំបន់ក្នុងខេត្តបាត់ដំបង ។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ការិយាល័យនេះរួមមានការិយាល័យនាយក ការិយាល័យនាយករង កម្មវិធីការពារ នីតិរដ្ឋ និងដីធ្លី និងការចិញ្ចឹមជីវិត និងមានអង្គភាពរដ្ឋបាលមួយ ។ ការិយាល័យបានបន្តស្ថិតក្នុងអន្តរកាលរង់ចាំការបញ្ចប់ការជ្រើសរើសបុគ្គលិកអន្តរជាតិ ស្របតាមអនុ-សាសន៍នៃការវាយតំលៃពីខាងក្រៅ កាលពីដើមឆ្នាំ២០០៤ ។ នៅពេលកំពុងធ្វើរបាយការណ៍នេះ ការិយាល័យមានបុគ្គលិកក្នុងស្រុកចំនួន១៩ នាក់ និងបុគ្គលិកអន្តរជាតិចំនួន៥ នាក់ ។ ការជ្រើសរើសបានបន្តធ្វើសំរាប់តំណែងដែលនៅទំនេរនៃបុគ្គលិកអន្តរជាតិ ។ មន្ត្រីរដ្ឋបាល បានចាកចេញពីការិយាល័យក្នុងខែវិច្ឆិកា ហើយការជ្រើសរើសមន្ត្រីមកជំនួសតំណែងនេះបានចាប់ផ្តើមធ្វើហើយ ។

៧៤. ប្រធានការិយាល័យទទួលខុសត្រូវចំពោះគោលនយោបាយ និងការគ្រប់គ្រងទូទៅ ។ ភារកិច្ចនេះរួមទាំងការជួយសំរបសំរួលដល់តំណាងពិសេសនៃលោកអគ្គលេខាធិការ ការចូលរួមក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ និងទំនាក់ទំនងអន្តរជាតិ និងជាមួយប្រទេសអ្នកផ្តល់ជំនួយ ។

៧៥. អនុប្រធានការិយាល័យទទួលខុសត្រូវក្នុងការសំរបសំរួលជាមួយកម្មវិធីទាំងឡាយដូចជា នីតិរដ្ឋ ការការពារ ការបោះឆ្នោត និងកិច្ចការរដ្ឋបាល ។

៧៦. កម្មវិធីការពារទទួលខុសត្រូវចំពោះករណីបណ្តឹង និងការឃ្លាំមើល ។ ការិយាល័យធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការនានា ដែលការពារសិទ្ធិមនុស្ស ។ ការិយាល័យក៏ផ្តោតផងដែរលើសេរីភាពក្នុងការបង្កើតសមាគម ការសំដែងមតិ និងការប្រជុំ ។

៧៧. កម្មវិធីនីតិរដ្ឋទទួលខុសត្រូវក្នុងការជួយពង្រឹងសមត្ថភាពស្ថាប័ន ច្បាប់ គោលនយោបាយ និងការអនុវត្តចាំបាច់សំរាប់ប្រតិបត្តិច្បាប់កម្ពុជា  កិច្ចព្រមព្រៀង និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិនានា ។

៧៨. កម្មវិធីដីធ្លី និងការចិញ្ចឹមជីវិតទទួលខុសត្រូវក្នុងការឃ្លាំមើលការអនុវត្តច្បាប់ និងគោលនយោបាយទាក់ទងនឹងដីធ្លី ឬផលប៉ះពាល់លើការប្រើប្រាស់ដីធ្លី និងប្រភពសំខាន់ៗដទៃទៀត នៃការចិញ្ចឹមជីវិត ។ ការិយាល័យធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការនានា ដែលការពារសិទ្ធិដីធ្លីរបស់សហគមន៍ ។

៧៩. អង្គភាពរដ្ឋបាលផ្តល់ការគាំទ្រផ្នែកបុគ្គលិក រដ្ឋបាល ហិរញ្ញវត្ថុ និងភស្តុភា ហើយបំពេញមុខនាទីជាមន្ត្រីស្នួលផ្នែកសន្តិសុខ ។

៨០. អង្គការសហប្រជាជាតិមានថវិកាទៀងទាត់សំរាប់ចំណាយលើប្រតិបត្តិការរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដោយរួមទាំងប្រាក់បៀវត្សរ៍របស់បុគ្គលិកអន្តរជាតិចំនួន ៧ រូប និងបុគ្គលិកក្នុងស្រុកចំនួន១៨ រូប ។ វិភាគទានស្ម័គ្រចិត្តចំពោះមូលនីធិទំនុកចិត្តអង្គការសហប្រជាជាតិ សំរាប់កម្មវិធីអប់រំសិទ្ធិមនុស្សនៅកម្ពុជា គ្រប់ដណ្តប់លើរាល់ការចំណាយផ្សេងៗ រួមទាំងសកម្មភាពកម្មវិធីធំៗ និងប្រាក់បៀវត្សរ៍របស់បុគ្គលិកទាំងឡាយ ដែលមិនស្ថិតក្រោមថវិកាទៀងទាត់ ។ មូលនីធិស្ម័គ្រចិត្តត្រូវបានគ្រប់គ្រងដោយការិយាល័យអង្គការសហប្រជាជាតិប្រចាំទីក្រុងហ្សឺណែវ ។

End.